# តួនាទីរបស់សហគមន៍និរទេសជន ក្នុងការស្វែងរកយុត្តិធម៌អន្តរកាល : គំរូនៃប្រទេសកម្ពុជា

ខែ កក្កដា ២០០៧

⁂

មាតិការឿង


**១. សេចក្តីផ្តើម** ..... ១

**២. សហគមន៍និរទេសជនកម្ពុជា ឬ ខ្សែបទនិទណ្ឌភាព/យុត្តិធម៌ ~ និហរណកម្មនៃបញ្ហាក្នុងស្រុកដែលស្រដៀងគ្នាដោយលក្ខណៈពិសេស នៃនិរទេសកម្ម** ..... ៨

ក. កត្តានៃការរារែក និង ការស្ទាក់ស្ទើររបស់សហគមន៍និរទេសជនក្នុងដំណើរការស្វែងរកយុត្តិធម៌ ..... ៩

ក₁. កត្តានៃការខ្វាចរអារ ចំពោះការសងសឹក និង ការបាក់ស្បាត ដែលលងចិត្ត ជានិច្ច ..... ៩

ក₂. ការរារែកបណ្តាលមកពីឧបសគ្គផ្លូវការចនាសម្ព័ន្ធក្នុងការបង្កើតសមាគមនានា : ការមិនចុះសម្រុងគ្នា និង កង្វះមធ្យោបាយ ..... ១២

ខ. ការគ្មានទំនាក់ទំនងគ្នា រវាងស្រគរមនុស្សពីរជំនាន់ ..... ១៤

**៣. ការចូលរួមរបស់សហគមន៍និរទេសជន ក្នុងការសំដែងមតិ និង ការប្តឹងទៅតុលាការ ដែលប្រព្រឹត្តនៅក្នុងប្រទេសជាម្ចាស់ផ្ទះ : ការផុសឡើងនូវភាគីថ្មីមួយ នៅលើឆាកតុលាការ** ..... ១៤

ក. ការផ្តួចផ្តើមគំនិតស្តីពីការងារតុលាការនិងទំនាក់ទំនងជាមួយស្ថាប័ននានា, ជាមួយប្រជាជនកម្ពុជា ក្នុងស្រុក ..... ១៥

ក₁. បណ្តឹងចំពោះតុលាការជាតិ ..... ១៥

ក₂. តួនាទី ក្នុងដំណើរការស្វែងរកយុត្តិធម៌ ចំពោះមុខតុលាការអន្តរជាតិ ..... ១៨

ខ. ការផ្តួចផ្តើមគំនិត ស្តីពីការងារផ្សព្វផ្សាយ និង ជូនពត៌មាន ..... ១៩

គ. តួនាទីគន្លឹះ នៃស្រគរមនុស្សជំនាន់ទីពីរ នៅក្នុងដំណើរការស្វែងរកការពិត ..... ២២

**៤. សហគមន៍និរទេសជន គឺជាសក្តានុពលមួយ ដែលត្រូវពង្រីកបន្ថែម** ..... ២៤

ក. កសាងប្រឆាំងនឹងភាពឯកោ របស់សហគមន៍និរទេសជន ..... ២៥

ខ. ធ្វើការផ្តួចផ្តើមគំនិតបន្ថែម ..... ២៧

គ. ស្វះស្វែងរកធនធាន អោយបានគ្រប់គ្រាន់ ដើម្បីធានានិរន្តរភាពនៃសកម្មភាព ..... ២៨

**៥. សេចក្តីសន្និដ្ឋាន** ..... ៣០

# ១. សេចក្តីផ្តើម

នៅទសវត្ស៦០ ក្រុមតូចមួយប្រកាន់លទ្ធិម៉ៅនិយមហួសហេតុត្រូវបានបង្កើតឡើង។ ក្រុមនេះឈ្មោះថា ខ្មែរក្រហមហើយដឹកនាំដោយ ប៉ុល ពត។ ជាដំបូង ក្រុមនេះប្រឆាំងនឹងរបបរបស់ស្តេច សីហនុ បន្ទាប់មក ក៏ប្រឆាំងនឹងរបបរបស់ ឧត្តមសេនីយ៍ លន់ ណុល។ ពួកខ្មែរក្រហម បានដណ្តើមអំណាចត្រួតត្រាក្រុងភ្នំពេញ នាថ្ងៃ ១៧ មេសា ១៩៧៥។ ចាប់តាំងពីព្រឹត្តិការណ៍នេះរហូតដល់ការដណ្តើមកាន់កាប់រាជធានីភ្នំពេញ ដោយកងទ័ពវៀតណាម នាថ្ងៃ ៧ មករា ១៩៧៩ មកពួកខ្មែរក្រហមបានប្រព្រឹត្តអំពើឃោរឃៅ បង្កអោយមានជនរងគ្រោះជិតពីរលាននាក់បានស្លាប់បាត់បង់ជីវិត។ ការដាក់អោយអនុវត្តនូវកម្មវិធីដ៏ធំធេងមួយសំដៅ អប់រំជាថ្មីចំពោះជនកម្ពុជា ដោយអនុវត្តតាមគំរូ នៃសង្គមកសិកម្ម របៀបជាសហករណ៍ គឺសំដៅកំទេចចោលអោយ អស់នូវឫសគល់វប្បធម៌របស់ប្រជាជនកម្ពុជា។ ក្រោយពីត្រូវបណ្តេញចេញពីទីក្រុងនានាមកប្រជាជនកម្ពុជាត្រូវបានចាត់តាំង រៀបចំ ជាសហករណ៍នៅតាមជនបទនានា ហើយត្រូវបង្ខំអោយធ្វើការជាទម្ងន់រហូតដល់ស្លាប់ ឬ បាក់កម្លាំង។ សហករណ៍ ទាំងនេះ គឺប្រៀបដូចជាជំរុំប្រមូលផ្តុំអញ្ចឹង ដោយអ្នកទោសត្រូវរងការអត់ឃ្លាន ជំងឺដង្កាត់ និង ការសម្លាប់គ្មានត្រាប្រណី។ ដោយបង្កើតអង្គភាពមួយដ៏មានអំណាចខ្លាំងក្លាបំផុត ហៅថាអង្គការ ដែលទទួលបន្ទុកគ្រប់គ្រងប្រទេសទាំងមូលនោះ ពួកខ្មែរក្រហមបានអនុវត្តនយោបាយឃោសនាមួយ និង ឯកោនិយម ដោយម៉្យាង គឺបិទទ្វារប្រទេសជិតឈឹង មិនទាក់ទងនឹងប្រទេសដទៃ ទៀតឡើយ និង ម៉្យាងទៀត គឺឯកោប្រជាជនកម្ពុជាទាំងស្រុង ដោយផ្តាច់ពីប្រភពពត៌មាន និង មធ្យោបាយទំនាក់ទំនង ទាំងអស់។ ដើម្បីអនុវត្តនយោបាយនេះ អោយល្អឥតខ្ចោះនោះ ពួកយោធា នៃរបបផ្តាច់ការនេះ បានសម្លាប់ជាលក្ខណៈប្រព័ន្ធ និង យ៉ាងងងឹតងងុល ចំពោះវណ្ណៈបញ្ញវ័ន្តខ្មែរទាំងមូល រួមទាំងអ្នកណា ដែលពួកវាយល់ថា ប្រឆាំងនឹងពួកវា, ពួកជនជាតិភាគតិច ដូចជា ចាម ជាដើម រហូតដល់ទាំងសង្ស័យ រួចសម្លាប់សមាជិកគ្នាវាផ្ទាល់តែម្តងផង។

ក្រោយពីកម្ពុជា ត្រូវបានរំដោះមក ជនភៀសខ្លួន បានភ្លូកទឹកភ្លូកដី រត់សំដៅទៅជំរុំនានា នៅក្នុងប្រទេសថៃ ដោយសង្ឃឹមថានឹងទទួលបានទិដ្ឋាការ ចេញទៅរស់នៅប្រទេសមួយផ្សេងទៀត។ ជនកម្ពុជាប្រហែល ៦០០ ០០០ នាក់ បានសំរេចចិត្តនិរទេសខ្លួន[១]។ ភាគច្រើននៃបញ្ញវ័ន្តកម្ពុជា ដែលចេះនិយាយភាសាបារាំង បានសំរេចទៅរស់នៅប្រទេសបារាំង។ សហរដ្ឋអាមេរិកទទួលយកភាគច្រើន ជាទាហាន និង កសិករ រួមនឹងសមាជិកគ្រួសាររបស់ពួកគេផង។ ចំណែកឯ ប្រទេសអូស្ត្រាលី និងកាណាដា ទទួលយកជនភៀសខ្លួនតិចតួចប៉ុណ្ណោះ។ គឺជាការពិតណាស់ ដែលពិបាកនឹងកំណត់ ចំនួនពិតប្រាកដនៃជនភៀសខ្លួនកម្ពុជា ដែលមកតាំងទីលំនៅ នៅប្រទេសបារាំង។ អ្នកខ្លះ វាយតម្លៃ ថាប្រហែលជា ៥០ ០០០ នាក់ នៅឆ្នាំ ១៩៨៩[២]។

---

[១] ស្តេហ្វានី ណាន់ *ជនកម្ពុជា នៅប្រទេសបារាំង, វាំងរូបភាព និង ការពិត,* ទស្សនាវដ្តី "សង្គមទេសន្តរប្រវេសន៍" ក្បាលទី ១៩ លេខ ១០៩ ចេញផ្សាយសំរាប់ ខែ មករា-កុម្ភៈ ២០០៧ ទំព័រ ១៥២។

[២] អ៊ីដា ស៊ីម៉ុន បារូហ៍ *ជនកម្ពុជា នៅប្រទេសបារាំង : អត្តសញ្ញាណថ្មី និង ផ្លាស់ប្តូរ* ទស្សនាវដ្តី "ជនទេសន្តរប្រវេសន៍ និង ការបណ្តុះបណ្តាល" លេខ ៧៦ ១៩៨៩ ទំព័រ ៧១។

តាមជំរឿនរបស់វិទ្យាស្ថានជាតិស្ថិតិ និង សិក្សាសេដ្ឋកិច្ច (INSEE[៣]) ចំនួនជនកម្ពុជា (ដោយរួម បញ្ចូលទាំងពួកអ្នកចូលសញ្ជាតិបារាំងផង) គឺមានចំនួន ៦៣ ២៨៤[៤] នាក់ នៅឆ្នាំ ១៩៩៩។ គេត្រូវរង់ចាំ រហូតដល់ឆ្នាំ ១៩៩៧ ទើបដំណើរការស្វែងរកយុត្តិធម៌ ប្រឆាំងពួកមេដឹកនាំខ្មែរក្រហមប្រល័យពូជសាសន៍ត្រូវបានផ្តួចផ្តើមឡើង ដោយសហប្រជាជាតិ តាមការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា។ ការបង្កើតសាលាក្តីកាត់ទោសពួកមេដឹកនាំខ្មែរក្រហម ត្រូវបានអនុម័តដោយច្បាប់មួយដែលប្រកាសអោយប្រើ នាថ្ងៃ ១០ សីហា ២០០១។ បន្ទាប់ពីការចរចាយ៉ាងយូរមក កិច្ចព្រមព្រៀងមួយស្តីពីការកាត់ទោសពួកជនដៃដល់នៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្រោមរបបខ្មែរក្រហម ក៏ត្រូវបានចុះហត្ថលេខា នាថ្ងៃ ៦ មិថុនា ២០០៣[៥] និងត្រូវបានផ្តល់សច្ចាប័ន ដោយប្រទេសកម្ពុជា នាថ្ងៃ ១៩ តុលា ២០០៤។ ដើម្បីធ្វើអោយច្បាប់កម្ពុជា ស្របទៅតាមច្បាប់អន្តរជាតិ ច្បាប់ចុះថ្ងៃ ១០ សីហា ២០០១ ស្តីពីការបង្កើតតុលាការកាត់ទោសពួកខ្មែរក្រហម ក៏ត្រូវបានធ្វើវិសោធនកម្ម នាថ្ងៃ ២៧ តុលា ២០០៤ ដែរ។ ទីបញ្ចប់ កិច្ចព្រមព្រៀងអន្តរជាតិនេះ ដែលកំណត់អំពីបែបបទ ធ្វើសហប្រតិបត្តិការអន្តរជាតិ និងដែលបញ្ជាក់ច្បាស់ពីស្តង់ដាអន្តរជាតិនោះ ក៏ក្លាយជាស្ថាពរនាថ្ងៃ ២៩ មេសា ២០០៥ ជាកាលបរិច្ឆេទ ដែលមូលនិធិចាំបាច់សំរាប់ការប្រព្រឹត្តទៅ នៃតុលាការកាត់ទោសពួកខ្មែរក្រហម ត្រូវបានប្រមូលបានហើយដែរ។

បើគិតតាមលក្ខណៈរចនាសម្ព័ន្ធ ប្រភេទនៃសាលាក្តីកាត់ទោសពួកខ្មែរក្រហម មានលក្ខណៈ ជាតុលាការកូនកាត់។ នៅដំណាក់កាលស៊ើបអង្កេត តុលាការនេះ មានចៅក្រមអន្តរជាតិចូលរួម ដោយឈរលើមូលដ្ឋានស្មើភាគគ្នា។ ផ្ទុយទៅវិញ នៅដំណាក់កាល កាត់ទោស ចំនួនចៅក្រមអន្តរជាតិ មានតិចជាងចំនួនចៅក្រមខ្មែរទៅវិញ[៦]។ សមត្ថកិច្ច នៃតុលាការនេះ គឺពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ (អំពើប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឧក្រិដ្ឋកម្មសង្គ្រាម ។ល។)[៧] និង ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ នៃច្បាប់កម្ពុជា ដែលប្រព្រឹត្តឡើង នៅចន្លោះ ថ្ងៃ ១៧ មេសា ១៩៧៥ និង ថ្ងៃ ៦ មករា ១៩៧៩[៨]។ ការចរចា ជាមួយរដ្ឋាភិបាលកម្ពុជា បានសំរេច កំណត់ព្រំដែនសមត្ថកិច្ចផ្ទាល់ របស់តុលាការនេះ ដើម្បីជៀសវាងបង្កបរិយាកាស ភ័យខ្លាចចំពោះ អតីតទាហានខ្មែរក្រហម ដូច្នេះហើយ តុលាការនេះ កាត់ទោសតែជនជាប់ចោទពី ៤ ទៅ ១០ នាក់ប៉ុណ្ណោះ។ ដើម្បីដំណើរការពេញលេញនោះ សាលាក្តីនេះត្រូវរង់ចាំការអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ដែលទីបញ្ចប់ត្រូវបានអនុម័ត នាថ្ងៃ

---

[៣] វិទ្យាស្ថានជាតិស្ថិតិ និង សិក្សាសេដ្ឋកិច្ច

[៤] ស្តេហ្វានី ណាន់ ដូចលើកឡើងខាងលើ ត្រង់ទំព័រ ១៤៩។

[៥] កិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការកាត់ទោសពួកជនដៃដល់ នៃឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើង ក្នុងជំនាន់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃ ៦ មិថុនា ២០០៣ ស្របតាមច្បាប់កម្ពុជា។ ឯកសារសហប្រជាជាតិ ចុះថ្ងៃ ១៣ មេសា ២០០៣ ស្តីពីការកាត់ទោសពួកខ្មែរក្រហម ដែលផ្តល់សច្ចាប័ន ដោយប្រទេសកម្ពុជា នាថ្ងៃ ១៩ តុលា ២០០៤ និង ចូលជាធរមាន ក្រោយពីសេចក្តីប្រកាសរបស់អគ្គលេខាធិការសហប្រជាជាតិ ថ្ងៃ ២៩ មេសា ២០០៥។

[៦] *ធនធានស្តីពីតុលាការវិសាមញ្ញកម្ពុជា* ដោយ ដាវិត បូល ។ http://www.ridi.org/boyle/infofcestruct.htm

[៧] មាត្រា ៤ ដល់ ៨ នៃច្បាប់ស្តីពីការបង្កើតតុលាការវិសាមញ្ញ នៅក្នុងផ្ទៃ នៃតុលាការកម្ពុជា ដើម្បីកាត់ទោសឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងជំនាន់ កម្ពុជាប្រជាធិបតេយ្យ ក្រមលេខ NS/RKM/0៨0១/១២ ចុះថ្ងៃ ១០ សីហា ២០០១ កែសំរួលដោយក្រម NS/RKM/១00៤/00៦ ប្រកាសអោយប្រើ នាថ្ងៃ ២៧ តុលា ២០០៤។

[៨] មាត្រា ៣ នៃច្បាប់ចែងខាងដើម។

១២ មិថុនា ២០០៧ និង ចូលជាធរមាន នាថ្ងៃ ១៩ មិថុនា[៩] ។ នៅឯបរទេសឯនោះ ទន្ទឹមនឹងការពិភាក្សាទាំងនោះ ពួកជនភៀសខ្លួន ដែលតាមដានការរីកចំរើននៃដំណើរការស្វែងរកយុត្តិធម៌ ក៏បានចាប់ផ្តើមប្រមូលគ្នាជាផ្លូវការឡើង។ ការបង្កើតសមាគមជនរងគ្រោះនៅប្រទេសបារាំង បានប្រព្រឹត្តទៅស្របពេលគ្នានឹងការបើកចរចាស្តីពីការកាត់ទោសមេដឹកនាំខ្មែរក្រហម នៅដើមទសវត្សឆ្នាំ ២០០០ (មានជាអាទិ៍ សមាគមគណៈកម្មាធិការជនរងគ្រោះដោយពួកខ្មែរក្រហម និង សមាគមជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍នៃពួកខ្មែរក្រហម...) ។ ប៉ុន្តែសមាគមជនរងគ្រោះនៅប្រទេសបែលហ្ស៊ិក ហៅកាត់ថា អាសូកា (ASSOCA) ត្រូវបានបង្កើតឡើង តាំងពីឆ្នាំ ១៩៩៩ គឺក្រោយពីអតីតមេដឹកនាំខ្មែរក្រហម ២ រូប គឺ ខៀវ សំផន និង នួន ជា បានចុះចូលជាមួយរដ្ឋាភិបាល ហ៊ុន សែន ម៉្លេះ។ ការចុះចូលនេះ គឺជាព្រឹត្តិការណ៍នាំអោយមានការដាក់ពាក្យបណ្តឹង ចំពោះតុលាការបែលហ្ស៊ិក។ ក៏ដូចគ្នានេះដែរ សមាគមស្វែងរកយុត្តិធម៌ សំរាប់កម្ពុជា[១០] ក៏ត្រូវបានបង្កើត នៅឆ្នាំ ២០០៥ ដែរ ពោលគឺបន្ទាប់ពីកិច្ចព្រមព្រៀង នាឆ្នាំ ២០០៣ រវាងសហប្រជាជាតិ និង រដ្ឋាភិបាល កម្ពុជា បានចូលជាធរមាន។

នៅក្នុងចលនាទាមទារមួយដ៏ធំទូលំទូលាយ នៅថ្ងៃ ៦ មិថុនា ២០០៥ សមាគមជាច្រើន, អង្គការមិនមែនរដ្ឋាភិបាលនានា, សមាគមនិស្សិត, មជ្ឈមណ្ឌលស្រាវជ្រាវ, សមាគមជនរងគ្រោះ ក៏ប្រជុំគ្នា នៅប្រទេសបារាំង ដើម្បីបង្កើត ជាសមូហភាព ឬ សហភាពជនរងគ្រោះដោយពួកខ្មែរក្រហម។ គោលដៅនៃសហភាពនេះ គឺបង្កការងាយស្រួលក្នុងការចូលរួមរបស់ជនរងគ្រោះ ក្នុងដំណើរការស្វែងរកយុត្តិធម៌ របស់តុលាការកាត់ទោសពួកខ្មែរក្រហម។ បច្ចុប្បន្ននេះ សហភាពនេះ រួមមាន សមាគមអាស៊ីជំនួយដល់យុវជន, សមាគមអាស៊ីខាងចុង, មជ្ឈមណ្ឌលស្រាវជ្រាវឧក្រិដ្ឋកម្មអន្តរជាតិ និង នៅអឺរ៉ុប, សមាគមកូណិចតេ, អង្គការកុមារនៃស្នាមញញឹមខ្មែរនិងយុត្តិធម៌សំរាប់ប្រទេសកម្ពុជា។ សហភាពនេះគឺជាអង្គការសកម្មជាងគេ បំផុត និង ប្រយុទ្ធជាងគេបំផុត នៃ សហគមន៍និរទេសជនកម្ពុជា នៅក្នុងដំណើរការ ស្វែងរកយុត្តិធម៌។

ការសិក្សានេះ គឺផ្តោតលើសហគមន៍និរទេសជនកម្ពុជា នៅប្រទេសបារាំង និង បែលហ្ស៊ិក និង ផ្តោតលើការប្តេជ្ញារបស់សហគមន៍នេះ ដើម្បីកាត់ទោសពួកមេដឹកនាំខ្មែរក្រហម[១១] ។ សហគមន៍និរទេសកម្ពុជានេះ ក៏អាចប្រៀបប្រដូចគ្នា ទៅនឹង

---

[៩] http://www.unakrt-online.org/Docs/Court%20Documents/2007-06-18%20IRs%20French.pdf

[១០] គោលបំណងរបស់សមាគមនេះ គឺអនុញ្ញាតអោយជនរងគ្រោះកម្ពុជា មិនថាជាពួកគេមានលំនៅស្ថាន នៅទីកន្លែងណាទេ អាចនឹងត្រូវតំណាង នៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ដោយធ្វើការផ្សាយពតិមាន ស្តីអំពីសិទ្ធិរបស់ពួកគេ និង ដើម្បីអោយជនរងគ្រោះទាំងនោះ ទាក់ទងជាមួយមេធាវីបារាំង និង មេធាវីបរទេស។ http://www.justicepourlecambodge.com

[១១] បន្ថែមលើប្រភពជាអត្ថបទ ការសិក្សានេះ ផ្អែកលើបទសន្ទនាពាក់កណ្តាលផ្ទាល់ ដែលធ្វើឡើងជាមួយ :

- សមាជិកមួយរូប នៃសមាគមគណកម្មាធិការជនរងគ្រោះ ដោយពួកខ្មែរក្រហម មានទីស្នាក់ការនៅក្រុងប៉ារីស៍។
- មេធាវីមួយរូប នៃសមាគមយុត្តិធម៌ សំរាប់ប្រទេសកម្ពុជា មានទីស្នាក់ការនៅក្រុងប៉ារីស៍។
- សមាជិកពីររូប នៃសមាគមជនរងគ្រោះអាសូកា មានទីស្នាក់ការនៅក្រុងព្រុចសែល ព្រមទាំងសមាជិកខ្លះៗ នៃគ្រួសាររបស់គាត់។
- សមាជិកពីររូប នៃបុគ្គលិកតុលាការកាត់ទោសពួកខ្មែរក្រហម នៅក្រុងភ្នំពេញ។
- សមាជិកមួយរូប នៃអង្គការអាដហុក មានទីស្នាក់នៅក្រុងភ្នំពេញ។ សមាជិកនេះ គឺជាសមាជិក នៃសហគមន៍និរទេសជនកម្ពុជា នៅប្រទេសបារាំង។

សហគមន៍និរទេសជនរ៉្វាន់ដា នៅប្រទេសបារាំង និង សហគមន៍និរទេសជនឈីលី នៅប្រទេសបែលហ្សិកដែរ។ ការប្រៀបធៀបនេះ ក៏អាចបញ្ជាក់ពី លក្ខណៈពិសេស ដែលបែងចែកគ្នាដាច់ស្រឡះ រវាងសហគមន៍ទាំងនេះដែរ។ ចំពោះសហគមន៍និរទេសជនរ៉្វាន់ដា គឺចន្លោះពេលខ្លី រវាងអំពើ ប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើងនៅឆ្នាំ ១៩៩៤ និង ការកាត់ទោស ដោយតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា (រយៈពេលខ្លីនេះ បានផ្តល់តួនាទីសំខាន់ដល់ជនរងគ្រោះផ្ទាល់ក្នុងការស្វែងរកយុត្តិធម៌ ជាជាងការចូលរួមរបស់ស្រទាប់មនុស្សជំនាន់ទី ២ នៃសហគមន៍និរទេសជនកម្ពុជា)។ ចំពោះជនឈីលីវិញ លក្ខណៈពិសេសរបស់ពួកគេ គឺស្ថិតនៅត្រង់មូលហេតុនៃនិរទេសកម្ម របស់ពួកគេ ពោលគឺ ដោយសារតែការបង្ក្រាបផ្នែកនយោបាយ ពីឆ្នាំ ១៩៧៣ ដល់ ១៩៨៨ ក្រោមរបបរបស់ឧត្តមសេនីយ ពីណូជេ។ ប្រការនេះ បាននាំអោយមានភាពខុសគ្នា យ៉ាងជាក់ស្តែង ទាំងផ្នែកទស្សនៈ ទាំងផ្នែកនៃការទាមទាររបស់ ជនភៀសខ្លួនរៀងៗខ្លួន។

សហគមន៍និរទេសជន ដែលជាភាគីមួយក្នុងដំណើរការស្វែងរកយុត្តិធម៌ គឺជាសក្តានុពលមួយដ៏សំខាន់ ដែលមិនទាន់ត្រូវបាន ប្រើអោយអស់លទ្ធភាពនៅឡើយ។ ប៉ុន្តែ តួនាទីរបស់សហគមន៍នេះ ក្នុងការប្រយុទ្ធប្រឆាំងនិទណ្ឌភាព គឺចាំបាច់ណាស់[១២] មានជា អាទិ តាមរយៈយន្តការតុលាការ ដូចជា តុលាការអន្តរជាតិជាដើម។

គំរូនៃសហគមន៍និរទេសជនកម្ពុជា គឺត្រូវបានចារឹកនៅក្នុងប្រពៃណីនយោបាយដ៏យូរលង់មកហើយរបស់សហគមន៍និរទេសជន។ ដំបូង មានឋានៈជាជនភៀសខ្លួន ហើយអស់រយៈពេលដ៏យូរ បុរស និង ស្ត្រី ទាំងនោះក៏ក្លាយជាក្រុមមួយដែលគេ

---

- សមាជិកមួយរូប នៃសហគមន៍និរទេសជនកម្ពុជា រស់នៅសហរដ្ឋអាមេរិក។
- គ្រួសារមួយ នៃជនភៀសខ្លួនកម្ពុជា រស់នៅប្រទេសបារាំង តាំងពីឆ្នាំ ១៩៨០ ហើយបដិសេធ មិនចុលរួម ជាសមាជិក នៃសមាគមជនរងគ្រោះ។
- ជនរងគ្រោះមួយរូប នៃសហគមន៍និរទេសជនឈីលី ដែលប្តឹមឧត្តមសេនីយពីណូជេ។ ជនរងក្រោះនេះ រស់នៅក្រុងព្រុចសែល។
- សមាជិកមួយរូប នៃសមាគម "សហភាពដើមបណ្តឹងរ៉្វាន់ដា" រស់នៅក្រុងរ៉ែម។
- សមាជិកមួយរូបនៃអង្គការក្រៅរដ្ឋាភិបាល យុត្តិធម៌ និងប្រជាធិបតេយ្យដែលទំនាក់ទំនងការងារជាមួយសហគមន៍និរទេសជនរ៉្វាន់ដា នៅប្រទេសបែលហ្សិក។

ការផ្លាស់ប្តូរមតិ ក៏ត្រូវធ្វើឡើងជាមួយភាគីដទៃៗទៀត ដែលមិនពាក់ព័ន្ធនឹងដំណើរការស្វែងរកយុត្តិធម៌ មានដូចជា មហាអយ្យការសហព័ន្ធ នៅក្រុងព្រុចសែល, អ្នកច្បាប់ជំនាញអំពីបរិបទនេះ ។ល។

ខ័ណ្ឌសីមា នៃការងារនេះ គឺស្ថិតនៅក្នុងដំណាក់កាលប្រមូលពតិមាន និង ការស្រង់សំដី ដែលជូនកាលនិយាយទាំងស្ទាក់ស្ទើរ។ ប៉ុន្តែ បើទោះជាយ៉ាងណាក្តី ការសំភាសន៍មនុស្សទាំងនោះ មិនមែនមានបំណងធ្វើឡើងអោយល្អឥតខ្ចោះ មានលក្ខណៈជាតំណាងពិតៗ អោយសហគមន៍និរទេសជនកម្ពុជា, រ៉្វាន់ដា និង ឈីលី នោះទេ (គឺសុទ្ធតែជាមជ្ឈដ្ឋាន ដែលមានទំនាស់បែកបាក់គ្នា)។ ការងារនេះ ក៏មិនអាចកំណត់មតិនានា អោយមានលក្ខណៈជាប្រព័ន្ធបានឡើយ។ លើសពីនេះទៀត គឺវិសាលភាពភូមិសាស្ត្រដ៏តូច នៃការសំភាសន៍ ដែលគ្រាន់តែធ្វើឡើង នៅតាមរដ្ឋធានីនានា គឺនៅក្រុងប៉ារីស៍ និង ក្រុងព្រុចសែល ក៏មិនអាចសរុបចរន្តមតិ របស់សហគមន៍កម្ពុជា នៅប្រទេសបារាំង និង បែលហ្សិកបានដែរ ម្យ៉ាងទៀត ដោយសារតែទីប្រជុំជនខេត្តនានា ក៏មានសមាគមជាច្រើន មានទីស្នាក់ការ នៅតាមខេត្តទាំងនោះដែរ។ ទីបំផុត បរិមាណដ៏តូច នៃការងារស្រាវជ្រាវ ដែលធ្វើឡើងជាមួយសមាគមទាំងនោះ ក៏ធ្វើអោយការវិភាគស៊ីជំរៅ និង ពិស្តារ អំពីជំហររបស់សមាគមទាំងនោះ មានជាអាទិ គឺជំហររបស់ស្រទាប់មនុស្សជំនាន់ទីពីរ មានការលំបាកដែរ។

[១២] យុគ ឆាំង, តុលាការអន្តរជាតិ និង និទណ្ឌភាព នៅកម្ពុជា : ករណីខ្មែរក្រហម, ស្វែងរកការពិត លេខ ១១ ខែ វិច្ឆិកា ២០០ ទំព័រ ២៨។

ប្រើពាក្យថា សហគមន៍និរទេសជន ពោលគឺ ជាវាក្យស័ព្ទមួយ មានន័យមិនច្បាស់លាស់ មានលក្ខណៈវិវត្តន៍ជានិច្ច[១៣] ។ បើទោះបី ជាតួនាទីរបស់សហគមន៍និរទេសជន នៅក្នុងទំនាក់ទំនងអន្តរជាតិ មិនមែនជាបាតុភូមិថ្មីប្លែកក្តី ក៏នៅក្នុងរយៈប៉ុន្មានទសវត្សរ៍ ចុងក្រោយនេះ បាតុភូតនេះបានរីកធំធាត់ គួរកត់សំគាល់ដែរ ។

ការរីកចំរើននៃសកម្មភាពនយោបាយនេះ គឺបណ្តាលមកពីមូលហេតុជាច្រើន : ការអភិវឌ្ឍនៃបច្ចេកទេសគមនាគមន៍, ការងាយស្រួលក្នុងការធ្វើដំណើរ, នយោបាយ ពហុវប្បធម៌ថ្មី របស់បណ្តារដ្ឋជាម្ចាស់ផ្ទះ ដែលគោរពចំពោះអត្តសញ្ញាណជនជាតិភាគតិច, កំណើនធនធានសេដ្ឋកិច្ច របស់ជនទេសន្តរប្រវេសន៍ ដែលកាន់តែកើនច្រើនឡើងៗ និង ការរីកចំរើន នៃលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសខ្លះៗ ដែល រហូតមកដល់បច្ចុប្បន្ននេះ បិទជិតឈឹង មានជាអាទិ នៅអឺរ៉ុបកណ្តាល និង អឺរ៉ុបខាងកើត[១៤] ។

ការចូលរួមនយោបាយលើឆាកអន្តរជាតិនេះ មានច្រើនប្រភេទណាស់ ។ ចំពោះសហគមន៍និរទេសជន គឺមានដូចតទៅ :

- អនុវត្តសកម្មភាពបញ្ចុះបញ្ចូល រដ្ឋជាម្ចាស់ផ្ទះ អោយគាំទ្រ ឬ អោយប្រឆាំង នឹងរដ្ឋដើមកំណើត ។
- គាបសង្កត់ប្រទេសដើមកំណើត ដោយគាំទ្រ ឬ ដោយប្រឆាំងរដ្ឋាភិបាលកំពុងកាន់អំណាច[១៥] ។ ការគាបសង្កត់នេះ ក៏ធ្វើឡើង ដោយការបញ្ជូនបេសកជនការទូត ឬ យោធា ទៅប្រទេសដើមកំណើតដែរ[១៦] ។
- បង្កើតជាឧបករណ៍មួយស្ថិតក្នុងដៃរបស់ប្រទេសជាម្ចាស់ផ្ទះ នៅក្នុងនយោបាយរបស់ខ្លួន ឬ ទំនាក់ទំនងរបស់ខ្លួន ជាមួយប្រទេសដើមកំណើត ។ បាតុភូតនេះ អាចនឹងមានលទ្ធភាពធ្វើបាន ដោយសារតែស្វ័យភាពនិយកម្មនៃសហគមន៍និរទេសជន[១៧] ខ្លះៗដោយសារតែផលប្រយោជន៍ផ្ទាល់ខ្លួន ដាច់ស្រឡះពីស្វ័យភាពនិយកម្មនៃប្រជាជននៅប្រទេសដើមកំណើត, កម្មវិធីជាក់លាក់ និង មតិនយោបាយជាក់លាក់[១៨] ។ គេគួរកត់សំគាល់ថា ការចូលរួមរបស់សហគមន៍និរទេសជន

---

[១៣] និយមន័យដំបូង នៃសហគមន៍និរទេសជន សុំអាន លីសា អងតឺប៊ិ យេមីនី, វីលីយ៉ាំ ប៉ែតូមីញ៉ែ ពិពណ៌នា និង យល់ដឹងអំពីសហគមន៍និរទេសជន ប្រវត្តិសាស្ត្រ ២០០០ ឆ្នាំ ក្រោមការដឹកនាំរបស់ លីសា អង់តឺប៊ិ យេមីនី, , វីលីយ៉ាំ ប៉ែតូមីញ៉ែ និង ហ្គាប្រិយ៉ែល សេហ្វ័រ សារពត៌មានសាកលវិទ្យាល័យ នៃក្រុងរ៉ែន ឆ្នាំ ២០០៥ ទំព័រ ៩ ។

[១៤] នីកូឡា វ៉ែតូវ៉ិច សារសំខាន់ផ្នែកនយោបាយរបស់សហគមន៍និរទេសជន៍ - វិទ្យាស្ថាននយោបាយទេសន្តរប្រវេសន៍ ប្រភពពត៌មានអំពីទេសន្តរប្រវេសន៍ ថ្ងៃ ១ មិថុនា ២០០៥ ។ http://www.migrationinformation.org/Feature/display.cfm?ID=313

[១៥] ដោយយោលទៅតាមប្រទេសនិមួយៗ ការចូលរួមរបស់សហគមន៍និរទេសជន មានកំរិតខុសៗគ្នា ។ ប្រទេសខ្លះ ដូចជា អ៊ីស្រាអែល បានចេញលុយទិញសំបុត្រយន្តហោះ អោយសមាជិក នៃសហគមន៍និរទេសជន ដើម្បីទៅចូលរួមក្នុងការបោះឆ្នោត ។ ចំណែកប្រទេសដទៃទៀត ដូចជា គ្រូអាស៊ី បានអនុញ្ញាតអោយបង្កើត តំណាងសហគមន៍និរទេសជន នៅក្នុងសភា ឬ នៅក្នុងរដ្ឋាភិបាលទៀតផង ។ សុំអានសៀវភៅរបស់លោកនីកូឡា វ៉ែតូវ៉ិច ។

[១៦] មីលតុន អ៊ីស្មាន់ សហហគមន៍និរទេសជន និង ទំនាក់ទំនងអន្តរជាតិ នៅក្នុងសៀវភៅ សហគមន៍និរទេសជនទំនើប នៅក្នុងនយោបាយអន្តរជាតិ ដោយលោក ហ្គាប្រិយ៉ែល សេហ្វ័រ គ្រុមហែល ក្រុងឡុង ១៩៨៦ ទំព័រ ៣៣៥

[១៧] សហគមន៍និរទេសជនអ៊ីរ៉ាក់ រស់នៅសហរដ្ឋអាមេរិក បានគាំទ្រនយោបាយសង្គ្រាម របស់រដ្ឋាភិបាលអាមេរិក នៅប្រទេសអ៊ីរ៉ាក់ ដោយចូលរួមក្នុងបក្សអភិរក្សថ្មី ។ គួរគួសបញ្ជាក់ថា ការបែកខ្ញែកមតិគ្នានេះ គឺបណ្តាលមកពីសមាជិកភាគខ្លះ នៃសហគមន៍និរទេសជន មិនដែលបានរស់នៅប្រទេសអ៊ីរ៉ាក់សោះឡើយ ឬ ក៏បានភៀសខ្លួន តាំងពីជាង ៤០ ឆ្នាំ មកម្ល៉េះ ។

[១៨] ហ្គាប្រិយ៉ែល សេហ្វ័រ នយោបាយសហគមន៍និរទេសជន នៅផ្ទះឯបរទេស សារពត៌មានសាកលវិទ្យាល័យកំប្រ៊ីត ២០០៣ ទំព័រ ៣០ ។

មិនមែនសុទ្ធតែផ្តល់ផលវិជ្ជមាននោះទេ ដោយសារតែសហគមន៍នេះមិនបានរងផលវិបាក ឬ ឆ្លងកាត់ទុក្ខវេទនាដោយសារនយោបាយ ដែលខ្លួនការពារនោះទេ។

- គាំទ្រភាគី ឬ បក្សនយោបាយ, ចលនាសង្គម ឬ ក៏សង្គមស៊ីវិល នៅក្នុងប្រទេសកំណើត។ ការប្រកាន់បក្សពួកនយោបាយរឹតតែខ្លាំងក្លាឡើង នៅក្នុងផ្ទៃក្នុងនៃសហគមន៍ ដែលភៀសខ្លួនចេញពីប្រទេសកំណើត ដោយសារមូលហេតុនយោបាយ[១៩]។
- គាំទ្រសកម្មភាពប្រើហិង្សា នៅក្នុងប្រទេសដើមកំណើត មានដូចជា ឧបត្ថម្ភហិរញ្ញវត្ថុ ដល់អង្គការប្រដាប់អាវុធ[២០]។ ផ្ទុយពីឧត្តមគតិរបស់ខ្លួន, ភក្តីភាពរបស់សហគមន៍និរទេសជន ចំពោះប្រទេសដើមកំណើត គឺគ្មានលក្ខណៈជាប្រព័ន្ធ និងពិបាកទទួលផលណាស់។ សហគមន៍និរទេសជន គឺជាភាគីមួយកាន់តែឯករាជ្យឡើងៗ ហើយសហគមន៍នេះនឹងក្លាយទៅជាបណ្តាញអង្គភាពស្វយ័ត[២១] គឺមិនមែនជាសាខានៅក្រៅប្រទេសនៃប្រទេសដើមកំណើតឡើយ។ តាមពិតទៅ ជួនកាលសហគមន៍និរទេសជន ក្លាយជាឧបសគ្គសំរាប់ប្រទេសដើមកំណើត ដែលចាត់ទុកសហគមន៍នេះ ជាសមាសភាពប្រឆាំងមួយមិនអាចគ្រប់គ្រងបាន។ បើទោះបីជាធនធានសេដ្ឋកិច្ច របស់សហគមន៍និរទេសជនមានច្រើនសំបើមយ៉ាងណាក្តី ចំពោះប្រទេសដើមកំណើត ក៏ប្រការនេះ មិនអាចរារាំងប្រទេសដើមកំណើត ក្នុងការរឹតព្រំដែនសិទ្ធិនយោបាយរបស់សហគមន៍នោះដែរ ដោយរារាំងមិនអោយ មានសិទ្ធិបោះឆ្នោត មិនអោយមានសញ្ជាតិ ពីរ ឬ ក៏មិនអោយមានសិទ្ធិ មានតំណាងនៅក្នុងសភា ដែលស្ថិតនៅក្នុង ប្រទេសដើមកំណើតដែរ។ ម៉្យាងទៀត ទំនាស់ក៏អាចនឹងកើតមាននៅផ្ទៃក្នុងរបស់សហគមន៍និរទេសជនខ្លួនឯងផងដែរ។ ប៉ុន្តែ ទោះបីជាមិនអាចបង្កើតបានជាប្លុកឯកភាពមួយក្តី ក៏សហគមន៍និរទេសជនត្រូវបានបំពាក់ដោយចរន្តនយោបាយដូចគ្នា ដូចដែលមានស្រាប់នៅក្នុងសង្គមដើមកំណើតរបស់ខ្លួនដែរ (សេរីនិយម/អភិរក្ស និយម, សាសនា/មិនជឿសាសនា។ល។[២២])

ការផ្តួចផ្តើមគំនិតត្រីភាគី (ប្រទេសម្ចាស់ផ្ទះ/ប្រទេសដើមកំណើត/សហគមន៍និរទេសជន) មានច្រើនណាស់ និង ខុសៗគ្នា ប៉ុន្តែមិនអាចនឹងយកមកពណ៌នា នៅក្នុងការសិក្សានេះទេ[២៣]។ ក្នុងគ្រប់ករណីទាំងអស់, កំលាំងរបស់សហគមន៍និរទេសជនត្រូវបាន ក៏រឹតព្រំដែន ដោយយោលទៅតាមលក្ខខណ្ឌ និង មូលហេតុមួយចំនួនដូចតទៅ :

---

[១៩] ហ្គាប្រិយែល សេហ្វ័រ នយោបាយសហគមន៍ជនជាតិភាគតិច ប្រវត្តិសាស្ត្រ ២០០០ ឆ្នាំ ក្រោមការដឹកនាំរបស់ លីសា អង់តឺប៊ី យេមីនី, វីលីយ៉ាំ ប៊ែតូមីញ៉ែ និង ហ្គាប្រិយែល សេហ្វ័រ សារពតិមានសាកលវិទ្យាល័យក្រុងរ៉ែន ២០០៥ ទំព័រ ១២៨។

[២០] សហគមន៍និរទេសជន អាចរួមចំណែកក្នុងការបំផុសសង្គ្រាម នៅក្នុងបរិបទ ដូចជា នៅប្រទេសអេធូពី, កូសូវ៉ូ, កាសឺមៀ, អ៊ីស្រាអែល, ប៉ាលេស្ទីន ។ល។ សូមអានសៀវភៅលោកនីកូឡា វ៉ែតូរ៉ិច។

[២១] ហ្គាប្រិយែល សេហ្វ័រ នយោបាយសហគមន៍និរទេសជន នៅផ្ទះឯបរទេស សារពតិមានសាកលវិទ្យាល័យកំប្រ៊ីត ២០០៣ ទំព័រ ២០៨។

[២២] ហ្គាប្រិយែល សេហ្វ័រ នយោបាយសហគមន៍ជនជាតិភាគតិច ប្រវត្តិសាស្ត្រ ២០០០ ឆ្នាំ ក្រោមការដឹកនាំរបស់ លីសា អង់តឺប៊ី យេមីនី, វីលីយ៉ាំ ប៊ែតូមីញ៉ែ និង ហ្គាប្រិយែល សេហ្វ័រ សារពតិមានសាកលវិទ្យាល័យក្រុងរ៉ែន ២០០៥ ទំព័រ ១២៩។

[២៣] មីលតុន អ៊ីស្មាន់ បានលើកឡើងគំនិតផ្តួចផ្តើម ៧ យ៉ាង ទំព័រ ៣៤០ ដល់ ៣៤៣។

- ក៏រិតវប្បធម៌, សំភារៈ និង ការចាត់តាំង ដែលមាននៅក្នុងក្រុម ។
- ឱកាស ដែលផ្ដល់អោយ ដោយប្រទេសជាម្ចាស់ផ្ទះ ក្នុងការលើកតំកើងផលប្រយោជន៍របស់សហគមន៍ ។
- ការជំរុញទឹកចិត្តអោយសមាជិកនានា ប្រមូលផ្ដុំគ្នាជាសហគមន៍មួយ និង រក្សាចំណងសាមគ្គីភាពជាមួយប្រទេសដើមកំណើត[២៤] ។

ដោយឃើញការវិវត្តន៍បែបនេះ បទពិសោធន៍របស់សហគមន៍និរទេសជនទាំងនេះ នៅក្នុងបរិបទអន្តរកាល គឺមានច្រើនយ៉ាង និង ទូលំទូលាយផង ។ តទៅនេះ យើងសុំលើកឡើងនូវឧទាហរណ៍សំខាន់ៗ ដូចតទៅ :

អំពីផែនការកាត់ទោសឧក្រិដ្ឋកម្ម :

- បើទោះបីជាមានទំនាស់ ដ៏ជ្រាលជ្រៅប្រឆាំងនឹងប្រទេសកំណើតរបស់ខ្លួនក្ដី ក៏ សហគមន៍អ៊ីរ៉ាក់ រស់នៅសហរដ្ឋអាមេរិក បានចូលរួមយ៉ាងខ្លាំងក្លាក្នុងការបង្កើតតុលាការពិសេសដែរ ក៏ដូចជាចូលរួមក្នុងកម្មវិធីសងជំងឺចិត្តចំពោះជនរងគ្រោះ[២៥] ដែរ ។
- សហគមន៍និរទេសជនឈីលី និង អាហ្សង់ទីន ក៏ប្រើប្រាស់ច្បាប់ស្ដីពី សមត្ថកិច្ចសាកល ដើម្បីឱតខំចាប់ខ្លួន និងកាត់ទោសពួកឧក្រិដ្ឋជន ដែលធ្វើដំណើរ នៅទ្វីបអឺរ៉ុបដែរ ។

អំពីផែនការស្វែងរកការពិត :

- សហគមន៍និរទេសជនអៃទី លេចធ្លោបំផុតក្នុងការចូលរួមបង្កើតគណកម្មាការស្វែងរកការពិត ទាំងអំពីបែបបទនៃការប្រព្រឹត្តទៅ ទាំងអំពីការងាររបស់គណៈកម្មាការនេះដែរ ។
- សហគមន៍និរទេសជនលីបេរីយ៉ា ក៏បានចូលរួមយ៉ាងជិតស្និទ្ធក្នុងដំណើរការស្វែងរកការពិតដែរ ។ តាមពិតទៅ គណៈកម្មាការ ស្វែងរកការពិត នៃប្រទេសលីបេរីយ៉ា មានគំរោងស្រង់យកបទបញ្ញត្តិ របស់និរទេសជនរស់នៅសហរដ្ឋអាមេរិក និង រស់នៅក្នុងជុំវិជនភៀសខ្លួន នៅក្នុងប្រទេសហ្កាណា[២៦] ទៀតផង ។

គឺស្ថិតក្នុងបរិបទនៃសន្ទុះបែបនេះឯង ដែលសហគមន៍និរទេសជនកម្ពុជា ធ្វើសកម្មភាពរបស់ខ្លួន ។ ករណីប្រទេសកម្ពុជា គឺស្ថិតក្នុងលក្ខណៈពិសេស ដោយសារការបំភ្លេចបាត់អំពើប្រល័យពូជសាសន៍អស់ជិត ៣០ ឆ្នាំ ទាំងផ្នែកតុលាការ ក៏ដូចផ្នែកឯកជនដែរ ។ អំពើអសកម្មនេះ គឺជារោគសញ្ញា នៃជំងឺដែលកប់ជ្រៅក្នុងសង្គមកម្ពុជា ក៏ដូចជាបណ្ដាលមកពីសមាសភាពនៃឆាកនយោបាយ ដែលនៅក្នុងនោះ ពួកអតីតមេដឹកនាំខ្មែរក្រហមសំខាន់ៗនៅបន្តកាន់កាប់តំណែងក្នុងរដ្ឋាភិបាលនៅឡើយ

---

[២៤] មីលតុន អ៊ីស្មាន់ ទំព័រ ៣៣៨ ។

[២៥] កម្មវិធីសងជំងឺចិត្ត រៀបចំឡើងនៅឆ្នាំ ២០០៤ តាមការផ្ដួចផ្ដើមរបស់សង្គមស៊ីវិល គឺមិនមែនជាកម្មវិធីរបស់រដ្ឋាភិបាលទេ ។

[២៦] ជាអាទិដោយសារជំនួយដែលផ្ដល់ដោយសមាគម Minnesota Advocates សំរាប់សិទ្ធិមនុស្ស ។ http://liberiatrc.mnadvocates.org/

ដែលជាហេតុធ្វើ អោយមានសម្លេងប្រឆាំងតិចតួច។ ការខ្លាចរអារចំពោះការសងសឹកនេះ ក៏កើតមាននៅឯបរទេសដែរ ដែលជាហេតុបង្កអោយមាន ជនភៀសខ្លួនជាច្រើនសន្ធឹកសន្ធាប់នោះ។

៣០ ឆ្នាំ ក្រោយពីអំពើប្រល័យពូជសាសន៏មក, ពន្លកនិង ក្តីសង្ឃឹម ក្នុងការស្វែងរកយុត្តិធមិ ក៏បានលេចឡើង។ វាត្រូវដល់ពេល នឹងវិភាគថា យ៉ាងដូចម្តេចដែរ បានជាជនរងគ្រោះ នៃសហគមន៏និរទេសជន ខ្លាចរអារដំណើរការស្វែងរកយុត្តិធមិនេះ។ ក្រោយពីបានកសាងជីវិតខ្លួនឡើងវិញ នៅក្នុងសង្គមមួយផ្សេង ក្រោយពីបានរៀបចំគ្រួសារ និង រស់រានដូចបានកើតលើកទី២ ជាមួយបុត្រីបុត្រា របស់ពួកខ្លួននោះ តើសហគមន៏ទាំងនេះ ផ្តល់តួនាទីយ៉ាងណា ចំពោះការស្វែងរកយុត្តិធមិ និង ជាពិសេស តើតុលាការ ផ្តល់តួនាទីដល់ពួកគេយ៉ាងណាដែរ? ជាដំបូង ជំហររបស់សហគមន៏និរទេសជន ចំពោះទ្វេបទនិទណ្ឌភាព/យុត្តិធមិ នឹងត្រូវបានកំណត់យ៉ាងជាក់ស្តែងឡើង។ តើអ្វីទៅ ជាការភ័យខ្លាច និង ជាក្តីសង្ឃឹមរបស់សហគមន៏ទាំងនេះ? បន្ទាប់មក ដោយឈរលើផែនការកាន់តែជាក់ស្តែង តើអ្វីទៅជាសមិទ្ធផល ដ៏ច្រើនសន្ធឹកសន្ធាប់ និង ប្លែកៗរបស់ជននិរទេសទាំងនេះ? ទីបំផុត ដើម្បីប្រើប្រាស់សក្តានុពល នៃសហគមន៏និរទេសជន អោយបានល្អប្រសើរនោះ តើមានវិធីកែលំអរអ្វីដែលអាចនឹងត្រូវស្នើឡើង?

## ២. សហគមន៍និរទេសជនកម្ពុជា ឬ ទ្វេបទនិទណ្ឌភាព/យុត្តិធម៌ ~ និហរណកម្មនៃបញ្ហាក្នុងស្រុក ដែលស្រដៀងគ្នាដោយលក្ខណៈពិសេស នៃនិរទេសកម្ម

បើទោះបីជា ចំណង់ចង់បានយុត្តិធមិមានពិប្រាកដមែន ក្នុងសហគមន៏និរទេសជនកម្ពុជាក្តី ក៏ការបាក់ទឹកចិត្តនៅចំពោះមុខនិទណ្ឌភាព ដែលស្ទើរមិនប្រែប្រួលនោះ ការភ័យខ្លាច និងឆន្ទៈចង់ បំភ្លេចចោល បានរាំងចំពោះគំនិតផ្តួចផ្តើមរបស់ជនរងគ្រោះដោយផ្ទាល់ដែរ។ បើទោះបីជាពិបាក នឹងកំណត់មតិក្តី ក៏គេ អាចកំណត់បាន នូវចរន្តធំៗ ៣ យ៉ាងរបស់សហគមន៏និរទេសជន បានដែរ : ១ គឺពួកមនុស្សដែលមិនចង់ ស្វែងរកយុត្តិធមិ (ពោលគឺពួកមនុស្សដែលប្រឡាក់ប្រឡូសក្នុងអំពើប្រល័យពូជសាសន៏ ដោយគេបង្ខំ ហើយគ្រាន់តែមានបំណងបំភ្លេចចោល) ២ គឺពួកមនុស្សដែលចង់បានយុត្តិធមិដែរ ប៉ុន្តែមិនហ៊ានចូលរួមទេ (ប្រភេទនេះ មានចំនួនច្រើនលើសលុប) និង ៣ គឺ ពួកមនុស្សជាតំណាង ដែលហ៊ានចេញមុខដើម្បីតវ៉ាយ៉ាងខ្លាំងក្លា ទាមទាររកយុត្តិធមិ។ មានកត្តាជាច្រើន ដែលរាំង ជនរស់រានមានជីវិតដែលនិរទេសខ្លួន ក្នុងការស្វែងរក យុត្តិធមិ។ ម៉្យាងគឺ ដោយសារឧបសគ្គផ្លូវចិត្ត (ការខ្លាចអំពើសងសឹក ជំងឺបាក់ស្បាត ។ល។) និងម៉្យាងទៀត គឺការលំបាក ក្នុងការរៀបចំចាត់តាំង និងកង្វះមធ្យោបាយសំភារៈ (កង្វះធនធានហិរញ្ញវត្ថុ និង ធនធានមនុស្ស, កង្វះការសំរបសំរួល និង បំផុសប្រមែប្រមូលគ្នា។ល។)។

## ក. កត្តារារាំង និង មិនអើពើរបស់សហគមន៍និរទេសជន ក្នុងដំណើរការស្វែង រកយុត្តិធម៌

### ក១. កត្តានៃការខ្លាចអំពើសងសឹកនិងជំងឺបាក់ស្បាតដែលចេះតែមកលងជានិច្ចជាកាល

មូលហេតុធំមួយ ក្នុងចំណោមមូលហេតុជាច្រើន នៃការរារែកក្នុងការចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌នោះ គឺជំងឺបាក់ស្បាតដ៏ធ្ងន់ធ្ងរ ដែលនៅតែបន្តបង្កការឈឺចាប់ចំពោះជនរស់រានមានជីវិត។ ជនរងគ្រោះខ្លះៗ ដែលត្រូវបានសំភាសន៍ បានពន្យល់បាតុភូតនេះ ថាមកពីកង្វះការព្យាបាលផ្លូវចិត្ត ពីសង្គមម្ចាស់ផ្ទះ ហើយអ្នកខ្លះទៀត ក៏បរិហារ ឬ បន្ទោសចំពោះការនៅស្ងៀមស្ងាត់ របស់សហគមន៍នេះ។ ម្យ៉ាងទៀត បើទោះបីជាមានភាពធ្ងន់ធ្ងរ នៃកាកសំណល់ នៃអំពើប្រល័យពូជសាសន៍ក្តី ក៏មានការលំបាកដោយសារតែមិនចេះភាសាបរទេស[២៧]។ ពួកជនរងគ្រោះស្ទើរមិនដែលលើកឡើងពីបទពិសោធន៍របស់ពួកខ្លួនសោះ ហើយជួនកាល រហូតដល់បដិសេធថាខ្លួន មិនមែនជាជនរងគ្រោះទៀតផង។ លើសពីនេះទៀត ការភ័យខ្លាចរបស់ជនរងគ្រោះ គឺបណ្តាលមកពីទោសកំហុសរបស់ពួកខ្លួន ដែលត្រូវបង្ខំអោយសហការជាមួយពួកខ្មែរក្រហម អោយប្រព្រឹត្តអំពើឃោរឃៅ។

ម្យ៉ាងទៀត ការភ័យខ្លាចអំពើសងសឹក ពេលប្តឹងទៅតុលាការ ឬ ក៏ពេលចូលជាសមាជិកសមាគមមួយក៏បានរារាំងដល់ជនរងគ្រោះខ្លះៗដែរ។ មនុស្សមួយចំនួន ដែលត្រូវបានធ្វើសំភាសន៍ បានអះអាងថា ដាក់ពាក្យបណ្តឹង ឬ ធ្វើជាសាក្សីមានគ្រោះថ្នាក់ខ្លាំងណាស់។ តាមពិតទៅ ជនរងគ្រោះទាំងនេះគ្មានជំនឿទុកចិត្តបន្តិចណាសោះចំពោះប្រព័ន្ធតុលាការ។ ការស្ថិតស្ថេរនៃសមាគមជនរងគ្រោះ គឺមានអាយុកាលខ្លី ដោយសារតែការបែកបាក់ទំនាក់ទំនងសង្គម ក្រោយពីអំពើប្រល័យពូជសាសន៍ ដែលជាហេតុជំរុញប្រជាជន អោយគិតគូរតែពីគ្រួសារស្នូល[២៨] តែប៉ុណ្ណោះ។ លើសពីនេះទៀត គឺចរិតបិទជិតរបស់សហគមន៍នេះ បានធ្វើអោយសហគមន៍នេះឯងក្លាយទៅជាកន្លែងទទួលពាក្យចចាមអារាម ដែលមានមូលដ្ឋានតិចតួច ហើយដែលកាន់តែធ្ងន់ធ្ងរថែមទៀតនេះ គឺពួកគេមើលឃើញប្រទេសកម្ពុជាបច្ចុប្បន្ន ថាដូចជាបិសាចអញ្ចឹង។

ម្យ៉ាងទៀត ការភ័យខ្លាចនេះ ក៏មានចរិតធម្មជាតិដែរ ដោយសារតែស្ថានការណ៍នយោបាយ នៃប្រទេសកម្ពុជា ដែលនៅមានអតីតខ្មែរក្រហម នៅបន្តកាន់កាប់មុខតំណែងសំខាន់ៗនៅក្នុងរដ្ឋាភិបាល។ ជនរងគ្រោះខ្លះៗដែលត្រូវបានសំភាសន៍ បានអះអាងថា មានការភ័យខ្លាចក្នុងការពាក់ព័ន្ធនឹងបុព្វហេតុមួយ ដែលអាចនាំអោយប៉ះពាល់ដល់ពួកមនុស្ស ដែលគេចាត់ទុកថាជាមនុស្សខ្លាំង និង គ្រោះថ្នាក់។ ស្ថានការណ៍នយោបាយនេះ បានរារាំងដល់ការហ៊ាននិយាយប្រឆាំង ទាំងនៅក្នុងប្រទេស ទាំងនៅក្នុងចំណោមសមាជិក នៃសហគមន៍និរទេសជន។

---

[២៧] បណ្ឌិត ព្យៃ ឌុយទែត ជនរងគ្រោះ ដោយប៉ុល ពត ទស្សនាវដ្តីជនរងគ្រោះ ដោយអំពើបង្ក្រាបរត់ភៀសខ្លួន (ក្រុងអាវ្រំ) លេខ ២២ តុលា ២០០០ ទំព័រ ៥។

[២៨] ម៉ារីស៍ អាលី តុលាការកម្ពុជា ដើម្បីកាត់ទោសពួកខ្មែរក្រហម ទស្សនាវដ្តីបែលហ្សិក អំពីច្បាប់អន្តរជាតិ លេខ ១-២ ឆ្នាំ ២០០៥ ទំព័រ ៦១០។

លើសពីនេះទៀត កង្វះការយកចិត្តទុកដាក់ និង កង្វះការចាប់អារម្មណ៍របស់សមាជិកខ្លះៗ នៃសហគមន៍និរទេសជនកម្ពុជា គឺបណ្តាលមកពី និទណ្ឌភាព តាំងពី ៣០ ឆ្នាំ មកហើយ។ ដោយដឹងថាខ្លួនខ្សោយ សមាជិកខ្លះ ក៏បោះបង់បុព្វហេតុនេះចោល ហើយជ្រើសរើស យកការបំភ្លេច និង ដូរទំព័រប្រវត្តិសាស្រ្ត។ ពាក្យចចាមអារាមថ្មីៗនេះ អំពីអំពើពុករលួយរបស់ចៅក្រមកម្ពុជា នៅក្នុងតុលាការកាត់ទោសខ្មែរក្រហម រឹតតែពង្រឹងការមិនទុកចិត្តរបស់ជនរងគ្រោះ ដែលយល់ឃើញថាការជ្រៀតជ្រែកនយោបាយ នាំអោយបាត់បង់ឯករាជភាព និង ភាពមិនលំអៀងរបស់ប្រពន្ធ័តុលាការ។

ប្រការនេះ គឺអាចប្រៀបធៀប បានជាមួយនឹងសហគមន៍និរទេសជនរ្វ៉ាន់ដា នៅប្រទេសបារាំងដែរ។ សមាគមជនរងគ្រោះរ្វ៉ាន់ដា ដែលត្រូវបានសំភាសន៏ សុទ្ធតែចង់កាត់ទោសពួកឧក្រិដ្ឋជន ដែលមានវត្តមាន នៅលើទឹកដីបារាំង។ នៅចំពោះមុខលទ្ធផលដ៏ស្តួចស្តើង ដែលទទួលបាន សមាគមនេះ ក៏បរិហារពីការខ្វះឆន្ទៈនយោបាយ នៅប្រទេសបារាំង ក្នុងការបំបែកសំណុំរឿងទាំងនេះ។ នៅក្នុងផ្ទៃក្នុងនៃសមាគមនេះ មានជនរងគ្រោះជាច្រើន បាក់ទឹកចិត្ត ហើយមិនចង់ចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌។ សមាជិកមួយរូប បានប្រកាសថា: *«ពួកអ្នកខ្លះបាននិយាយមុនគេ ដោយជឿថា ការធ្វើជាសាក្សីរបស់ខ្លួន នឹងបំរើអោយការរកយុត្តិធម៏។ ដោយគ្មានឃើញលទ្ធផលអ្វីសោះនោះ ពួកគេក៏រារែកដោយនិយាយថា គ្មានបានការអ្វីទេ។ ឧបសគ្គធំជាងគេនោះ គឺការមើលអ្វីៗមិនដើរទៅមុខក្នុងការស្វែងរកយុត្តិធម៌›* ។ នៅចំពោះមុខនិទណ្ឌភាពគឺវាជៀសមិនផុតទេ ដែលការទាមទាររកយុត្តិធម៏ ត្រូវស្រុតចុះបន្តិចម្តងៗ រហូតដល់ភាគីខ្លះវិលទៅរកជំហរ ឬ តួនាទីជាអ្នកសង្កេតការណ៏វិញ។ សមាគមជនរងគ្រោះរ្វ៉ាន់ដា ក៏សួរខ្លួនឯងថា: *«នៅក្នុងផ្ទៃក្នុងនៃសមាគមយើងបានខិតខំជូនពត៌មាន ស្តីពីដំណើរការទៅមុខរបស់តុលាការ។ តើពត៌មានទាំងនេះ ត្រូវបានទទួលយ៉ាង ដូចម្តេច? តើពត៌មានទាំងនេះ គួរជាទីចាប់អារម្មណ៏ឬទេ? ជួនកាល គេអាចមន្ទិលសង្ស័យលើពត៌មានទាំងនេះផង»* ។

ទីបំផុត ការទទួលស្គាល់លក្ខន្តិកៈ ជាជនរងគ្រោះ គឺសំខាន់ណាស់ សំរាប់បំផុសចំណង់ស្វែងរកយុត្តិធម៌។ គំរូនៃជនរងគ្រោះឈីលី ដោយអំពើបង្រ្កាបខាងនយោបាយ មានលក្ខណៈជាក់ស្តែងណាស់។ ក្នុងរឿងក្តីពីណូជេ ជនភៀសខ្លួននយោបាយ ដែលត្រូវបានស្តារនិតិសម្បទា និង ត្រូវចាត់ទុកជាវីរបុរស បានផ្តល់បទពិសោធន៏របស់ពួកគេ និង កេណ្ឌកម្លាំងយ៉ាងប្តូរផ្តាច់ក្នុងការស្វែងរកយុត្តិធម៌ ដែលកាលពីមុនវិញ ជនរងគ្រោះទាំងនោះ *«ត្រូវបានបដិសេធចោល បំភ្លេចចោល សុទ្ធតែខុសច្បាប់ទាំងគ្រប់ករណី*[២៩] *»* សុទ្ធតែជាពិរុទ្ធជន ដោយសារតែបាននិរទេសខ្លួន ឬ ក៏បានបរាជ័យក្នុងការតស៊ូនយោបាយ។ ដូច្នេះហើយ ករណី ពីណូជេ ក៏បានអនុញ្ញាតអោយជនរងគ្រោះឈីលីបានបន្លឺសម្លេងឡើង ក្នុងឆាកនយោបាយ។

---

[២៩] ហ្វាន់នី ជេតលីគី ជននិរទេសឈីលី និង ករណីពីណូជេ ការវិលត្រឡប់ និង ការបញ្ជូនសារណា សៀវភៅរបស់ អៀមីស ថ្ងៃ ៧ មិថុនា ២០០១ ទំព័រ ៥៩។

តាមការសង្កេត ទំងន់នៃជំនឿសាសនា ដើរតួនាទីដ៏សំខាន់ ក្នុងការស្វែងរកយុត្តិធម៌។ បើសិន ជាពុទ្ធសាសនិកទាំងអស់សុទ្ធតែឯកភាពថា តាមទ្រឹស្តីកម្មពៀរ គឺថាពួកឧក្រិដ្ឋជនទាំងអស់ នឹងត្រូវផ្តន្ទាទោសនៅជាតិក្រោយ ដូច្នេះមតិស្តីពីលទ្ធភាពកាត់ទោសពួកឧក្រិដ្ឋជន មានត្រូវខុសៗគ្នា។ មតិទីមួយយល់ថា ការកាត់ទោសពួកឧក្រិដ្ឋជន គឺជាការសងសឹក ហើយវាគ្រាន់តែបង្កើតអោយមានវដ្តនៃការឈឺចាប់[៣០] តែប៉ុណ្ណោះ។ មតិមួយផ្សេងទៀត គាំទ្រការកាត់ទោសក្នុងលក្ខខណ្ឌ ដែលការកាត់ទោសនេះ ប្រព្រឹត្តទៅដោយគ្មានលំអៀង និង ដោយស្របទៅតាមគោលការណ៍ពុទ្ធសាសនា និង ស្តង់ដារអន្តរជាតិ[៣១]។ មតិដែលអត់អោនទោសពួកកូនទាហាន (ដោយការសារភាព និង ការសុំអភ័យទោស) គឺអាចទទួលយកបាន ប៉ុន្តែអភ័យទោសអោយពួកមេដឹកនាំខ្មែរក្រហម គឺមិនអាចទទួលយកបានទេ[៣២]។ ផ្ទុយទៅវិញ បើតាមអ្នកនិពន្ធខ្លះ គេយល់ថាការអភ័យទោស គឺជាទស្សនទានរបស់ប្រទេសប្រកាន់សាសនាគ្រឹស្តពីបស្ចិមប្រទេស[៣៣]។ ពោលគឺគ្មានសមមូលនៃការអភ័យទោសនៅក្នុងពុទ្ធសាសនាទេ[៣៤]។ អ្នកដទៃទៀត ទទួលស្គាល់ថា ការអភ័យទោស គឺជាអំណាចសង្គ្រោះ ចំពោះ មនុស្សប្រុស ឬស្រីណា ដែលផ្តល់អោយការអភ័យទោសនេះ ហើយនេះ គឺមិនថាផលកម្មអ្វី ដែលអាចកើតឡើងចំពោះមនុស្ស ដែលទទួលបានការអភ័យទោសឡើយ។ ទ្រឹស្តីសាសនា និង វប្បធម៌ ត្រូវតែទទួលបានការយកចិត្តទុកដាក់នៅក្នុងដំណើរការស្វែងរកយុត្តិធម៌។

---

[៣០] ករណីព្រះសង្ឃទេព វង្ស ស្តេចសង្ឃគណៈមហានិកាយ សូមអានសៀវភៅ របស់លោកហ្វ្រង់ស្វ័រ ប៉ុងសូ ការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម អ៊ិនទៃណេត បេសកកម្មសាសនាបរទេសប៉ារីស៍ ៣ កុម្ភៈ ២០០៧។ http://phnompenh.mepasie.net/jugement-des-ex-responsables-khmers-rouges.fr-fr.48.54.content.htm

[៣១] ក្រេក អេតឆីសុន ប្រពៃណី និង ការសំរុះសំរួល នៅប្រទេសកម្ពុជា សាលាសិក្សាអន្តរជាតិ ២០០៤។

[៣២] ‹‹ស្ថិតនៅក្នុងករណីទាំងនេះ អ្នកសម្ភាសន៍ទាំងនោះ គាំទ្រការលើកលែងទោស ដោយបកស្រាយការលើកលែងទោស តាមទស្សនៈព្រះពុទ្ធសាសនា។ ជំនឿដែលថាៈ "ការចងពៀរ រមែងបំបាត់ដោយការមិនចងពៀរ" ត្រូវបានរំលឹកជាច្រើនដង ដោយអ្នកសម្ភាសន៍។ កត្តាសំខាន់ ដែលគួរអោយកត់សំគាល់ គឺថាជំនឿក្នុងការលើកលែងទោសនេះ មិនបានប៉ះពាល់ដល់មេដឹកនាំកំពូលទេ។ *[...]* ដូច្នេះ បើទោះបីជាមនុស្សទាំងនេះប្រតិបត្តិ នៅក្រោម ការអធិប្បាយ យ៉ាងជាក់លាក់ពីពុទ្ធសាសនិកក្តី និងពីទស្សនៈពិភពលោកក្តី ក៏គេមិនដែលទំលាប់ធ្វើការការលើកលែងទោសទេ"។ ›› ជាយ៉ា រ៉ែមជី កែប្រែប្រវត្តិសាស្ត្រកម្ពុជាៈ ករណីពិតប្រាកនៃបេសកកម្ម សមោសរដ្ឋហ្វ្រិកឈី នៃកិច្ចការសារពត៌មានពិភពលោក និទាឃរដូវ ឆ្នាំ ២០០០។

[៣៣] តេរ៉ាសា ក្លូស្ទែម៉ាន់ ការប្រព្រឹត្តទៅបាន និង សមរម្យ នៃបេសកកម្មដ៏ពិតប្រាកដៈ ក្នុងប្រទេសកម្ពុជា, មិនយឺតពេក, មិនលឿនពេក?, សារពត៌មានអារីហ្សូណា នៃច្បាប់អន្តរជាតិ និង ច្បាប់សាជីវកម្ម, ១៩៩៨។

[៣៤] ‹‹សង្គមខ្មែរ គឺជាសង្គមមួយ ដែលគ្មានសញ្ញាណបុគ្គលៈ សត្វលោកគ្រាន់តែជាវត្ថុនៃថាមពល មិនទៀងទាត់ បណ្តោះអាសន្ន គ្មានបច្ច័យ។ ជីវិត គឺគ្រាន់តែជាដំណាក់កាលនៃការសិរិតសំរាំងខ្លួនប្រាណប៉ុណ្ណោះ។ ថាមពលជីវិត មានបន្ទុកវិជ្ជមាន ឬ អវិជ្ជមាន ដោយយោលទៅតាមអំពើ ដែលប្រព្រឹត្ត រហូតដល់អស់កម្មពៀរទាំងអស់ គឺមានច្រើនជាតិណាស់។ ដូច្នេះ តាមទ្រឹស្តីនេះ គឺគ្មានការអភ័យទោសទេ។ "គឺអ្នកណាស៊ី អ្នកនោះឯងឆ្អែត" "អ្នកណាធ្វើល្អ ទទួលផលល្អ អ្នកណាធ្វើអាក្រក់ ទទួលផលអាក្រក់ គ្មានការអប់រំជាថ្មី អាចធ្វើទៅកើតទេ ពីព្រោះ កម្មពៀរវាអន្ទោលតាមសត្វលោក ដូចស្រមោលអញ្ចឹង។›› ហ្វ្រង់ស្វ័រ ប៉ុសូ។

### ក២. ការរារាំងរកបណ្ដាលមកពីឧបសគ្គផ្នែករចនាសម្ព័ន្ធ ក្នុងការបង្កើតសមាគមនានា : ការមិនចុះសម្រុងគ្នា និងកង្វះមធ្យោបាយ

ក្នុងចំណោមចំណុចខ្សោយធ្ងន់ធ្ងរបំផុតរបស់សហគមន៍ជនរងគ្រោះ គឺមានការបែកបាក់និងទំនាស់។ សហគមន៍និរទេសជនកម្ពុជា នៅប្រទេសបារាំង រួមមានជនភៀសខ្លួនកម្ពុជា ដែលមានវប្បធម៌ខ្ពស់ ហើយភាគច្រើនសុទ្ធតែជាមនុស្សមានជីវភាពមធ្យម។ កំរិតវប្បធម៌ទាបរបស់សមាជិក បានរារាំងក្នុងកំរិតណាមួយនោះមិនអោយមានគំនិតផ្តួចផ្តើម មិនអោយមានប្រតិកម្ម មិនអោយមានសមត្ថភាព ក្នុងការប្រមូលកម្លាំង និងយល់ដឹងអំពីច្បាប់។ ដូច្នេះហើយ ក្នុងការទាមទារយុត្តិធម៌របស់សហគមន៍និរទេសជន គឺអាស្រ័យជាចំបងទៅលើកំរិត វប្បធម៌របស់សមាជិកនិមួយៗ។ គួរកត់សំគាល់ថា សហគមន៍និរទេសជនឈីលីដែលមានសុទ្ធតែពួកអតីតអ្នកប្រឆាំង នយោបាយ គឺមានកំរិតវប្បធម៌ខ្ពស់ណាស់[៣៥]។ អញ្ចឹងហើយបានជាសហគមន៍នេះចេះសំរបសំរួលអោយមានការប្រមូលផ្តុំជនរងគ្រោះ នៅទ្វីបអឺរ៉ុបទាំងមូល និងចេះធ្វើការផ្តួចផ្តើមគំនិតយ៉ាងប៉ិនប្រសប់។ ការបង្កើតបណ្តាញសមាគមជនរងគ្រោះឈីលី បានបង្កអោយមានការកោះប្រជុំវេទិកាដ៏ធំមួយដើម្បីធ្វើការពិភាក្សា និង ផ្លាស់ប្តូរមតិគ្នា។

លើសពីនេះទៀត ការអូសទាញសមាជិកនានា នៃសហគមន៍និរទេសជន អោយចូលរួមក្នុងសមាគមជនរងគ្រោះ គឺតំរូវជាមុនអោយទទួលបានជំនឿទុកចិត្ត ពីសមាជិកទាំងនោះ។ សមាគមនេះ ត្រូវតែគួរជាទីទុកចិត្ត និង ស្របច្បាប់ផង។ ចំពោះសហគមន៍និរទេសជនកម្ពុជា បញ្ហាជំនឿទុកចិត្ត គឺចោទជាការលំបាកពិតៗ ដោយសារតែទំនាស់ផ្ទៃក្នុង ដែលកើតឡើងក្នុងសហគមន៍នេះ។ ទំនាស់នេះ បង្កអោយមានការបង្កើតសមាគមជាច្រើន ដែលតាមពិត ជាការធ្វើអោយទំងន់នៃការទាមទារ ចុះខ្សោយទៅវិញទេ។

កង្វះមធ្យោបាយហិរញ្ញវត្ថុ សំភារៈ និង ធនធានមនុស្ស បានបង្កការរាំងស្ទះដល់សកម្មភាពរបស់សហគមន៍។ សហគមន៍និរទេសជនកម្ពុជា ឈីលី និង រ៉្វាន់ដា អាចលើកគំរោងបាន តែដោយសារថវិកាផ្ទាល់ខ្លួន ដែលបានពីវិភាគទានរបស់សមាជិកខ្លួនប៉ុណ្ណោះ។ សហគមន៍ទាំងនេះ គ្មានបានទទួលការឧបត្ថម្ភហិរញ្ញវត្ថុ ពីរដ្ឋាភិបាលឡើយ។ ដើម្បី អង្គៀសប្រាក់ សហគមន៍ទាំងនោះ ក៏រៀបចំអោយមានព្រឹត្តិការណ៍ផ្សេងៗ ដូចរាត្រីស្រមោលសវប្បធម៌ និង នាទីសន្ទនា ជាដើម។ ជនរងគ្រោះកម្ពុជាមួយរូប ដែលត្រូវបានសំភាសន៍ បានអះអាងថា ការបរាជ័យក្នុងការប្តឹងទៅតុលាការនៅក្នុងប្រទេសជាម្ចាស់ផ្ទះ គឺបណ្តាលមកពីប្រទេសជាម្ចាស់ផ្ទះនេះទាមទារសោហ៊ុយពីអ្នកដើមបណ្តឹង។ លើសពីនេះពួកអ្នកស្ម័គ្រចិត្តធ្វើការក្នុងសហគមន៍ ធ្វើសកម្មភាពតែក្រោយពីធ្វើការចិញ្ចឹមជីវិតរបស់ខ្លួនរួចហើយ និង ធ្វើការនៅពេលវិស្សមកាលផង។ ដូច្នេះ ដោយត្រូវប្រឈមមុខនឹងជីវភាពប្រចាំថ្ងៃ នៅក្នុងប្រទេសជាម្ចាស់ផ្ទះផង ពួកអ្នកស្ម័គ្រចិត្តទាំងនោះគ្មានទាំងពេលវេលា ទាំងមធ្យោបាយសំរាប់ធ្វើការ

---

[៣៥] ហ្វាន់នី ចេតលិកគី ដូចលើកពីខាងដើម ទំព័រ ៥៨។

អោយខ្ចាប់ខ្លួន និង ខ្លាំងក្លាបានទេ។ ដូចជា សមាគមយុត្តិធមិសំរាប់ប្រទេសកម្ពុជាជាដើម ដែលធ្វើការយ៉ាងសកម្មនៅក្នុងសហភាពជនរងគ្រោះដោយខ្មែរក្រហម គឺដំណើរការបានតែដោយសារសុឆន្ទៈរបស់សមាជិកខ្លួន និង មេធាវីស្ម័គ្រចិត្តប៉ុណ្ណោះ។ កង្វះមធ្យោបាយនេះ ដែលអូសបន្លាយយូរទៅ អាចនឹងធ្វើអោយជនរងគ្រោះបាក់ទឹកចិត្ត និងរារែក។ សមាជិកមួយរូបនៃសមាគមជនរងគ្រោះវ៉ាន់ដា បានធ្វើការកត់សំគាល់ថាៈ *‹‹នៅក្នុងសហគមន៍ និវទេសជនវ៉ាន់ដាមានមនុស្សតិចណាស់ ដែលប្រយុទ្ធជាក់ស្តែង ក្នុងការស្វែងរកយុត្តិធមិ : ជាការប្រយុទ្ធយូរអង្វែង ដែលទាមទារអោយចំណាយពេលវេលាយូរ ទាំងប្រាក់កាសផង។ មនុស្សភាគច្រើន សុខចិត្តនៅរង់ចាំមើលអ្វីៗ ដំណើរការសិន។ យុត្តិធមិគឺជាការប្រយុទ្ធមួយ ដែលទាមទារកម្លាំងលើសពីកម្លាំងមនុស្សទៅទៀត ពោលគឺជាកម្លាំង ដែលជនរងគ្រោះគ្មាន ពីព្រោះពួកគេត្រូវប្រឈមមុខនឹងបញ្ហាជាក់ស្តែង ជាច្រើន នៃជីវភាពប្រចាំថ្ងៃ។ ››*

ដោយគ្មានបទបញ្ញត្តិណាសោះ ស្តីពីការទទួលបន្ទុករបស់តុលាការកាត់ទោសខ្មែរក្រហម ក្នុងការចេញសោហ៊ុយធ្វើដំណើរអោយជនរងគ្រោះ និងសាក្សីនោះ ពួកជនភៀសខ្លួន ក៏កាន់តែបារម្ភ អំពីសោហ៊ុយជាយថាហេតុ ដែលពួកខ្លួនត្រូវរ៉ាប់រងហើយប្រការនេះ ក៏បានក្លាយជាកត្តាបាក់ទឹកចិត្តដែរ។

ការចូលរួម របស់សហគមន៍និវទេសជនកម្ពុជា មានលក្ខណៈពីរយ៉ាង។ ម្យ៉ាង គឺសហគមន៍នេះ លើកឡើងអំពីជំងឺបាក់ស្បាតអំពីការបាក់ទឹកចិត្ត និង ការភ័យខ្លាចអំពីការសងសឹក របស់ជនរងគ្រោះផ្ទាល់ ដែលជាការបង្អាក់គំនិតផ្តួចផ្តើម ស្វែងរកយុត្តិធមិ និង ម្យ៉ាងទៀត គឺចំនាប់អារម្មណ៍របស់ស្រករមនុស្សជំនាន់ទី២ ចំពោះប្រធានបទនេះ ដែលគេកំរលើកឡើងណាស់។

## ខ. ការស្ងៀមស្ងាត់រវាងស្រករមនុស្សពីរជំនាន់

បញ្ហាទី២ គឺជាបញ្ហាកង្វះការសិក្សា ស្តីពីអំពើប្រល័យពូជសាសន៍ រវាងពួកជនរងគ្រោះផ្ទាល់ និង បុត្រីបុត្រា របស់ពួកគាត់ទាំងនៅក្នុងចំណោមប្រជាជនកម្ពុជាក្នុងស្រុក ។ នេះដែលហេតុបណ្តាលអោយមានផលវិបាករួមផង និង ផលវិបាកដោយឡែកផង។

បច្ចុប្បន្ននេះ ជិត ៥០% នៃប្រជាជនកម្ពុជា មានអាយុតិចជាង ១៨ ឆ្នាំ។ បាតុភូតនេះ គឺបណ្តាលមកពីការសម្លាប់រង្គាល ស្ទើរគ្រប់ស្រករមនុស្ស ដោយរបបប្រល័យពូជសាសន៍ និង ដោយសារកំណើនខ្ពស់ នៃអត្រាកំណើត ក្រោយពីការរំដោះប្រទេសកម្ពុជា។ ប៉ុន្តែ ទាំងផ្នែកឯកជន ទាំងផ្នែកសាធារណៈ ជនរងគ្រោះសុទ្ធតែនៅស្ងៀមស្ងាត់ មិននិយាយអំពីទុក្ខវេទនារបស់ពួកខ្លួន នៅក្រោមរបបខ្មែរក្រហមឡើយ។ ដូចជាកម្មវិធីសិក្សា ក៏មិនបានបរិយាយអំពីដំណាក់កាលខ្មៅងងឹតនៃប្រវត្តិសាស្ត្រនេះដែរ ចំណែកឯនៅតាមគេហដ្ឋានវិញ ក៏មាតាបិតា មិនសូវបានលើកនិយាយពីទុក្ខវេទនានេះដែរ។ ប្រការនេះ គឺមកពីមូលហេតុ ច្រើនយ៉ាង : បំណងចង់បំភ្លេចចោលអំពើឃោរឃៅ ការខ្មាស់អៀន បំណងមិនចង់បញ្ជូនការឈឺចាប់ និងភាពល្ងីងល្ងង់ចិត្តនេះ។ល។ បាតុភូតនេះ ក៏កើតមានចំពោះជនរងគ្រោះឈីលី ដោយអំពើបង្ក្រាបដែរ : ‹‹

*ពួកជនភៀសខ្លួនឃើលី ដែលរងទុក្ខដោយអនុស្សាវរីយ៍ខ្លោចផ្សារនោះ មិនងាយនឹងនិយាយអំពីទុក្ខវេទនារបស់ខ្លួន ប្រាប់កូនចៅទេ។ សេចក្តីភ័យខ្លាច វាធ្វើអោយពិបាកនឹងថ្លែងវាចាប្រាប់កូនចៅ ក្នុងនាមជាឪពុក ឬ ជាម្តាយ តើនឹងត្រូវផ្តល់រូបភាពនៃជនរងគ្រោះលំបាកវេទនា យ៉ាងដូចម្តេចទៅ? ជាទូទៅ ពួកជនភៀសខ្លួនឃើលីសុខចិត្តមិន "បំពុល" បុត្រធីតារបស់គេដោយសារតែប្រវត្តិឃោរឃៅ ឬ ក៏បំផុសមនោសញ្ចេតនាចងគំនុំ ឬ ក៏ពោលពាក្យប្រមាថធ្ងន់ៗ ឡើយ។ ដូច្នេះ គឺវាមានការ ខ្វះអៀនពិតៗមួយ ឬ ក៏អលទ្ធភាពមួយ ក្នុងការនិយាយពីវគ្គខ្លះៗ នៃប្រវត្តិរបស់ឪពុកម្តាយ។ អញ្ចឹង ហើយបានជាសារណា ត្រូវបានលើកឡើង ដោយសំដីដាច់ៗ របៀបភ្លេចមុខ ភ្លេចក្រោយ ជួនកាល ទាំងភូតកុហកផង*[៣៦] »។ ដោយប្រឈមមុខចំពោះការនៅ ស្ងៀមស្ងាត់នេះ ដោយរស់នៅក្នុងសង្គមមួយដែលបាត់បង់ឫសគុល បាត់បង់អត្តសញ្ញាណ និងសេចក្តីថ្លៃថ្នូរ យុវជនកម្ពុជា បានប្រតិកម្មតបនឹងប្រវត្តិសាស្ត្រនេះ របៀបពីរយ៉ាងផ្ទុយគ្នា : មួយគឺ ការនៅស្ងៀមស្ងាត់ ឬ ទីពីរ ប្រមូលកម្លាំងដើម្បីស្វែង រកការពិត និង ក្តាប់យកប្រវត្តិសាស្ត្ររបស់ខ្លួន។

បើសិនជានៅប្រទេសកម្ពុជា យុវជនស្ថិតនៅក្នុងភាពមិនយល់ មិនដឹង អំពីអំពើប្រល័យពូជសាសន៍ ឯចំណែកយុវជន ( ស្រករជំនាន់ទី២) នៃសហគមន៍និរទេសជនកម្ពុជាវិញ បាកសិក្សាតាំងពីក្មេងៗម្ល៉េះ អំពីប្រវត្តិឃោរឃៅ និង អំពើប្រល័យពូជសាសន៍ តាមសភាវគតិ យុវជនយល់ពីទុក្ខសោក របស់មាតាបិតា របស់ខ្លួន ហើយក៏គោរពបំណងចង់នៅស្ងៀមស្ងាត់ របស់ពួកលោក។ ក្រោយមក យុវជនទាំងនោះ បានដឹងនៅសាលា ឬ ក៏បានដឹងពីមិត្តភក្តិវិញ នូវទុក្ខវេទនាទាំងនោះ។ ការសិក្សានៅសាលា និង ការមើលពតិមាន នៅក្នុងបណ្តាញពតិមានសាធារណៈ ស្តីពីបញ្ហាទុក្ខវេទនានេះ បានដើរតួនាទីដ៏សំខាន់ ក្នុងការអោយយុវជនទាំងនោះ ប្រមូលកម្លាំង និង ការយល់ដឹង ថាពួកគេពិតជាមានការពាក់ព័ន្ធនឹងបញ្ហាទាំងនេះ[៣៧]។ ការបើកការកាត់ទោសពួកខ្មែរក្រហមគឺជាឱកាសសំខាន់សំរាប់បើកការពិភាក្សា និងជំរុញយុវជនអោយសួរខ្លួនឯងអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។ ក៏ដូចគ្នានេះដែរ រឿងក្តីពីណូចេក៏បានដើរតួនាទីដ៏សំខាន់សំរាប់បុត្រីបុត្រានៃនិរទេសជនឃើលី ជំរុញអោយពួកនេះគេស្វះស្វែងរកយុត្តិធម៌ និងចង់ស្វែងយល់អោយបានច្បាស់អំពីការពិតនៃប្រទេសកំណើតរបស់ពួកគេ។

## ៣. ការចូលរួមរបស់សហគមន៍និរទេសជនក្នុងការសំដែងមតិនិងការប្តឹងទៅតុលាការដែលប្រព្រឹត្តនៅក្នុងប្រទេសជាម្ចាស់ផ្ទះ : ការផុសឡើងនូវភាគីថ្មីមួយនៅលើឆាកតុលាការ

បើទោះបីជាមានការភ័យខ្លាច របស់ជនរងគ្រោះ ភាគច្រើន រស់នៅឯបរទេសក្តី ក៏គំនិតផ្តួចផ្តើម ដើម្បីស្វែងរកយុត្តិធម៌ បានកើតមានដែរ។ សកម្មភាពផ្នែកផ្លូវច្បាប់ និង សកម្មភាពផ្សព្វផ្សាយ និង ជូនពតិមាន ដល់សមាជិកនានាក្នុងសហគមន៍ ជូនដល់ប្រទេសជាម្ចាស់ផ្ទះ ក៏ត្រូវបានធ្វើឡើង ស្របពេលជាមួយគ្នា តាមរយៈស្ថាប័នអន្តរជាតិ។ ដោយឆ្លៀតឱកាស ដែលមាន

[៣៦] ហ្វាន់នី ជេតលិកគី ដូចលើកខាងដើម ទំព័រ ៦៧។

[៣៧] ហ្វានី ជេតលិកគី ដូចលើកឡើងខាងដើម ទំព័រ ៧០។

សេរីភាពកាន់តែច្រើនឡើង សហគមន៍និរទេសជន បានរៀនជាបណ្តើរៗ ដើម្បីទម្លាប់ប្រើឧបករណ៍ និង អនុវត្តច្បាប់ ដែលប្រទេសជាម្ចាស់ផ្ទះ ផ្តល់អោយខ្លួន និង ទម្លាប់បញ្ចេញមតិ (ដែលមានតិច នៅប្រទេសកម្ពុជា) ដើម្បីទាមទារអោយមានលទ្ធិប្រជាធិបតេយ្យ កាន់តែច្រើនឡើង នៅក្នុងប្រទេសកំណើតរបស់ខ្លួន។ ធ្វើរបៀបនេះ សហគមន៍និរទេសជន អាចនឹងដើរតួជាអ្នកនាំពាក្យរបស់ប្រជាជនកម្ពុជាក្នុងស្រុក ដែលត្រូវបិទមាត់ ដោយសារមូលហេតុនយោបាយ។

## ក. ការផ្តួចផ្តើមគំនិតស្តីពីការខារតុលាការ និង ទំនាក់ទំនងសហគមន៍និរទេសជនរបស់ជាមួយស្ថាប័ននានា និង ជាមួយ ប្រជាជនកម្ពុជាក្នុងស្រុក

### ក១. បណ្តឹងចំពោះតុលាការជាតិ

មានពាក្យបណ្តឹងជាច្រើនប្រភេទ ត្រូវបានដាក់ជូនតុលាការជាតិបែលហ្សិកនិងបារាំង។ ពាក្យបណ្តឹងទាំងនោះបានរួមចំណែកក្នុងដំណើរការស្វែងរកយុត្តិធម៌ ម៉្យាងដោយប្រមូលភស្តុតាងដ៏មានប្រយោជន៍ជួយដល់ការងាររបស់តុលាការកាត់ទោសពួកខ្មែរក្រហម និងម៉្យាងទៀត ដោយបង្កឥទ្ធិពលជានិមិត្តរូបផង។

ការចុះចូលជាមួយរដ្ឋាភិបាល របស់អតីតមេដឹកនាំខ្មែរក្រហមពីររូប គឺ ខៀវ សំផន (អតីតប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ) និង នួន ជា (អតីតអគ្គលេខាធិការរងបក្ស) កាលពីខែធ្នូ ១៩៩៨ បានបង្កការជ្រួលជ្រើមមួយពិតៗ នៅក្នុងផ្ទៃនៃសហគមន៍និរទេសជនកម្ពុជា[៣៨]។ បើតាមក្រុមអ្នកជំនាញការ ដែលលោកអគ្គលេខាធិការសហប្រជាជាតិបញ្ជូនទៅប្រទេសកម្ពុជាមុននេះបន្តិច គឺនៅខែវិច្ឆិកា ១៩៩៨នោះ ព្រឹត្តិការណ៍នេះ គឺជាអាទិភាពមួយរបស់រដ្ឋាភិបាល ដើម្បីកំចាត់ចោលការគំរាមកំហែងយោធា របស់ពួកខ្មែរក្រហម។ យុទ្ធសាស្ត្រនេះ គឺសំដៅផ្តល់ការលើកលែងទោស អោយពួកមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្ម ដែលពួកវាបានប្រព្រឹត្ត ក្នុងពេលដែលពួកវាកាន់អំណាច ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩[៣៩]។ តាមពិត ជាក់ស្តែង គឺមានតែមេដឹកនាំខ្មែរក្រហមតែពីរនាក់ប៉ុណ្ណោះ ដែលត្រូវចាប់ខ្លួននិងដាក់ក្នុងពន្ធនាគារ។ ម្នាក់គឺតាម៉ុកជាមេដឹកនាំខ្មែរក្រហមដ៏សំខាន់ ស្លាប់នៅខែ កក្កដា ២០០៦ និង ម្នាក់ទៀត គឺឌុច ជាអតីតមេគុកទួលស្លែង ត្រូវចាប់ខ្លួន ក្រោយពីការចុះចូលរបស់ខៀវ សំផង និង នួន ជា។

ក្រោយពីការចុះចូលនេះមក ក៏មានពាក្យបណ្តឹងទីមួយ ប្រឆាំងពួកខ្មែរក្រហម។ ពាក្យបណ្តឹងបែបនេះ មិនធ្លាប់ដែលមានសោះហើយត្រូវបានផ្តើមគំនិតដោយជនរងគ្រោះនៃសហគមន៍ខ្មែរនៅប្រទេសបែលហ្សិក[៤០]។ ពាក្យបណ្តឹងនេះត្រូវបានដាក់នៅក្រុងព្រុចសែល ដោយ ១៧ គ្រួសារ នៃសមាគមសាមគ្គីម្ពុជា ហៅកាត់ថា អាសូកា នាថ្ងៃ ៤ កុម្ភៈ ១៩៩៩។ ពាក្យបណ្តឹង នេះ

[៣៨] ស៊ីលវ៉ែន ប៉ាសគៀ ទំនាក់ទំនងដ៏គ្រោះថ្នាក់របស់ ហ៊ុន សែន ទស្សនាវដ្តី Express ចេញថ្ងៃ ៨/១/១៩៩៩ ទំព័រ ៤៨។

[៣៩] របាយការណ៍របស់ក្រុមជំនាញការ ចុះថ្ងៃទី ១៩៩៩ ទំព័រ ២៩។

[៤០] ប៉ាទ្រីស ឡឺប្រាំង តុលាការបែលហ្សិកកាត់ទោសអំពើប្រល័យពូជសាសន៍ខ្មែរក្រហម កាសែតឡឺស្វ័រ ចេញថ្ងៃ ៥/០២/១៩៩៩។

ប្ដឹងមេដឹកនាំខ្មែរក្រហមបីនាក់ គឺ ខៀវ សំផន, នួន ជា និង អៀង សារី ( អតីតរដ្ឋមន្ត្រីការបរទេសនៃកម្ពុជា ប្រជាធិបតេយ្យ) ចំពោះឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មនៃច្បាប់អន្តរជាតិ និង ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[៤១] ។
តាមរយៈសេចក្ដីថ្លែងការណ៍ ជំរាបពតិមាននោះ ជនរងគ្រោះទាមទារអោយទទួលស្គាល់ :

*« ១. ចរិតប្រល័យពូជសាសន៍ នៃការសម្លាប់រង្គាល ចំពោះបុរស ស្ត្រី និង កុមារ ដែលប្រព្រឹត្តឡើង នៅប្រទេសកម្ពុជា ក្រោមការជិះជាន់របស់ពួកខ្មែរក្រហម ។*

*២. ការទទួលខុសត្រូវទូទៅ របស់ពួកខ្មែរក្រហមនិងការទទួលខុសត្រូវ ដោយឡែករបស់ពួកមេដឹកនាំខ្មែរក្រហមនិងពួកអ្នកសមគំនិត ក្នុងឧក្រិដ្ឋកម្មនេះ ។*

*៣. គ្រោះថ្នាក់ចំពោះប្រជាជនកម្ពុជាបច្ចុប្បន្ន នៃការវិលត្រឡប់ប្រកបដោយការគំរាមកំហែង នៃឥទ្ធិពលខ្មែរក្រហមនៅក្នុងចំណោមថ្នាក់ដឹកនាំប្រទេស » ។*

គួរកំណត់សំគាល់ថា នៅខែ សីហា ១៩៩៦ រដ្ឋាភិបាលកម្ពុជា បានផ្ដល់ការលើកលែងទោស រួចទៅហើ យអោយ អៀង សារី អតីតរដ្ឋមន្ត្រីការបរទេសខ្មែរក្រហម ។
តាមរយៈការទាមទារទាំងនេះ ជនរងគ្រោះ បានអះអាងយ៉ាងដាច់អហង្ការ ចង់កាត់ទោសពួកឧក្រិដ្ឋជន និង ប្រឆាំងដាច់ខាតចំពោះការវិលត្រឡប់ របស់អតីតមេដឹកនាំខ្មែរក្រហម ក្នុងឆាកនយោបាយកម្ពុជា។ ដូច្នេះ គេកត់សំគាល់ឃើញថាមានការប្ដេជ្ញា របស់សហគមន៍និរទេសជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ផង និង ចង់ប្រលូកក្នុងឆាកនយោបាយដោយប្រយោលផង ។

ពួកអ្នកប្ដឹងសង្ឃឹមថានឹងមានដីកាអន្តរជាតិចាប់ខ្លួនដើម្បីកិរិតព្រំដែនធ្វើដំណើររបស់ពួកចុងចោទ ក៏ដូចជាបញ្ជូនគណៈកម្មាការចៅក្រមស៊ើបអង្កេតមួយ ទៅប្រទេសកម្ពុជា ដើម្បីប្រមូលភ័ស្ដុតាង និង កសិណសាក្សី[៤២] ។ ពីរខែក្រោយពីការដាក់ពាក្យបណ្ដឹងមក មានគ្រួសារបារាំងដើមកំណើតខ្មែរជាច្រើន បានចូលរួមក្នុងការប្ដឹង។ ប្រទេសបារាំងមិនបានផ្ដល់ឱកាសបែបហ្នឹងទេ។ ការស៊ើបអង្កេត ដែលចាប់ផ្ដើមនៅខែ មេសា ១៩៩៩ នោះ ក៏បានធ្វើឡើងចំពោះឃាតកម្ម លើជន បែលហ្សិក ពីរនាក់ដែលត្រូវសម្លាប់នៅប្រទេសកម្ពុជា កាលជំនាន់[៤៣] នោះដែរ។ ក្នុងក្របខ័ណ្ឌ នៃពាក្យបណ្ដឹងនេះ ដីកាអន្តរជាតិចាប់ខ្លួន ឌុច ក៏ត្រូវបានចេញដែរ ប៉ុន្តែ នៅតែមិនត្រូវបានអនុវត្ត រហូតមកដល់សព្វថ្ងៃ ដោយសារ ឌុច ត្រូវចាប់ ខ្លួន ដោយអាជ្ញាធរកម្ពុជារួចទៅហើយ។ បច្ចុប្បន្ននេះ ការស៊ើបអង្កេតអំពីពាក្យបណ្ដឹងនេះ ក៏ នៅតែដំណើរការនៅឡើយដែរ បើទោះបីជាពាក្យបណ្ដឹងនេះ ត្រូវកប់ចោលដោយសារការមិនអនុវត្តដីកាចាប់ខ្លួនក្ដី ។

---

[៤១] សាប៊ីន វៃរ៉េស ពាក្យបណ្ដឹងប្រឆាំងពួកខ្មែរក្រហម កាសែតបែលហ្សិកសេរី ចេញថ្ងៃ ៥/០២/១៩៩៩ ទំព័រ ៥។

[៤២] សាប៊ីន វៃរ៉េស ដូចលើកឡើងខាងដើម.

[៤៣] ដាមីញាង វ៉ាន់ឌ៉ែមាច កាសែតនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ខែ មេសា ២០០៥។

មេធាវីរបស់ដើមបណ្តឹង បានប្រកាសចំពោះសារពត៌មាន នៅពេលដាក់ពាក្យបណ្តឹងថា *«បើសិនជាតុលាការអន្តរជាតិកាត់ទោសពួកមេដឹកនាំខ្មែរក្រហមក្តី ក៏សំណុំរឿងនេះ ដែលស៊ើបអង្កេតដោយតុលាការបែលហ្សិកនៅតែរក្សាទុកនិងអាចប្រើជាមូលដ្ឋាន នៃការងារកាត់ទោសដែរ»*។ ស្របនឹងពេលបង្កើតតុលាការកាត់ទោសពួកខ្មែរក្រហម សំណុំរឿងនេះ ប្រហែលជានឹងត្រូវផ្ទេរទៅអោយតុលាការនេះ។ ចំណែកឯភ័ស្តុតាងនិងកសិណសាក្សីដែលប្រមូលបាន ក៏នឹងប្រើប្រាស់ជាប្រយោជន៍បន្ទាប់បន្សំដែរ។ ដូច្នេះ ត្រូវរង់ចាំដល់តុលាការកាត់ទោសពួកខ្មែរក្រហមធ្វើការងារយ៉ាងពេញបន្ទុកសិន ទើបដឹងរឿងនេះ។ ទោះយ៉ាងណាក្តី ក៏ពាក្យបណ្តឹងនេះ បង្កអោយមានការប្រមូលកម្លាំង និង ការរួបរួមគ្នា ដ៏សំខាន់របស់ជនរងគ្រោះនៅប្រទេសបែលហ្សិក និង បារាំងដែរ ដែលកាលពីមុនបែកបាក់គ្នា ដោយសារទស្សនៈនយោបាយ[៤៤]។

ពាក្យបណ្តឹងទីពីរ ប្តឹងពីឈ្មោះ x ត្រូវបានដាក់នៅប្រទេសបារាំង កាលពីខែ តុលា ១៩៩៩ ដោយលោកស្រីមេម៉ាយ អ៊ឹង ប៊ុនហោ អតីតប្រធានសភាជាតិ។ តាមការរៀបរាប់ លោកអ៊ឹង ប៊ុនហោ បានរត់ទៅជ្រកកោន នៅស្ថានទូតបារាំង ពេលដែលពួកខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ នាថ្ងៃ ១៧ មេសា ១៩៧៥។ លោកបានចុះចូល ឬ ក៏ត្រូវប្រគល់ខ្លួនអោយទៅពួកខ្មែរក្រហម (ត្រង់នេះហើយ ជាកម្មវត្ថុនៃបណ្តឹង)។ ពាក្យបណ្តឹងនេះ ត្រូវតែយកមកលាតត្រដាង ពីព្រោះតាមការអង្កេតរដ្ឋបារាំងបានយល់ព្រមអោយបើកកកាយការសម្ងាត់ ស្តីពីឯកសារសម្ងាត់ របស់នាយកដ្ឋានត្រួតពិនិត្យដែនដី តាមការស្នើសុំរបស់ចៅក្រមស៊ើបអង្កេត។ សំណុំរឿងនេះ រួមមានពត៌មានប្លែកៗ ស្តីពីព្រឹត្តិការណ៍ ដែលកើតឡើងនៅក្រុងភ្នំពេញ ក្នុងរយៈពេលបីសប្តាហ៍មុនពេលពួកខ្មែរក្រហមដណ្តើមកាន់កាប់ក្រុងភ្នំពេញ រហូតដល់ជនជាតិបារាំងចុងក្រោយបង្អស់ ជន្លៀសចេញទៅប្រទេសថៃ។ ដូច្នេះពត៌មានទាំងនេះ អាចនឹងផ្តល់សេចក្តីបំភ្លឺជាប្រវត្តិសាស្ត្របាន និង អាចជាឯកសារដ៏សំខាន់ដល់ដំណើរការកាត់ ទោសពួកមេដឹកនាំខ្មែរក្រហម[៤៥]។

## ក២. តួនាទី ក្នុងដំណើរការស្វែងរកយុត្តិធម៌ ដោយតុលាការអន្តរជាតិ

*នៅអមតុលាការកាត់ទោសពួកខ្មែរក្រហម*

វាជាការលឿនពេក ក្នុងការបញ្ជាក់អំពីរូបភាព នៃសហការរវាងសហភាពជនរងគ្រោះ ដោយពួកខ្មែរក្រហមនិងតុលាការកាត់ទោសពួកខ្មែរក្រហម ប៉ុន្តែអង្គភាពទាំងពីរនេះ អាចមានទំនាក់ទំនង តាមរូបភាពជាការពិគ្រោះ ឬ ទំនាក់ទំនងក្រៅផ្លូវការរវាងគ្នា។ ជាឧទាហរណ៍ នៅខែ ឧសភា ២០០៦ គណៈប្រតិភូតំណាងសហភាពជនរងគ្រោះ បានជួបសមាជិកជាច្រើន នៃរដ្ឋាភិបាលកម្ពុជា នៅប្រទេសកម្ពុជា ដូចជាលោក ឧបនាយករដ្ឋមន្ត្រី សុខ អាន និង លោក រដ្ឋមន្ត្រីយុត្តិធម៌អង់ វង្សវឌ្ឍនា ជាដើម ដើម្បីប្រគល់សៀវភៅស របស់សហភាពជនរងគ្រោះ ស្តីពីសិទ្ធិរបស់ជនរងគ្រោះ។ សៀវភៅសនេះ ក៏ត្រូវបានប្រគល់ជូនតំណាងនៃតុលាការកាត់ទោសពួកខ្មែរក្រហមដែរ។

---

[៤៤] វ៉ែល ប៊ីល ថ្ងៃ ៦-៧ កុម្ភៈ ១៩៩៩

[៤៥] ពីយ៉ូត ស្វង្សា ភ្នំពេញ ១៩៧៥ : រាត្រីក្រហមនៅលើស្ថានទូត កាសែតឡឺម៉ុង ចេញថ្ងៃ ១៦ មករា ២០០៧។

ក្រៅពីនេះ កាលពីខែ វិច្ឆិកា ២០០៦ សហភាពជនរងគ្រោះ ក៏ផ្តល់អនុសាសន៍ ស្តីពីគំរោងវិធានផ្ទៃក្នុង របស់តុលាការកាត់ទោសពួកខ្មែរក្រហមដែរ ដែលនៅពេលនោះ បញ្ហាតំណាងរបស់ជនរងគ្រោះ តំលាភាពនៃនិតិវិធី លទ្ធភាពបោះពុម្ពផ្សាយមតិប្រឆាំង បែបបទនៃកសិណសាក្សី និងបញ្ហាដ៏ស្រួចស្រាវនៃការសងជំងឺចិត្ត ក៏ត្រូវបានលើកឡើងមក ពិភាក្សាដែរ។ ដោយឡែក ជំនួបនិងការផ្លាស់ប្តូរមតិក្រៅផ្លូវការក៏ត្រូវបានធ្វើឡើងដែរ ដែលជាហេតុផ្តល់ដល់សហភាពជនរងគ្រោះនូវតួនាទីមួយក្នុងដំណើរការស្វែងរកយុត្តិធម៌។

*នៅអមជាប់នឹងប្រជាជនក្នុងស្រុក*

ទំនាក់ទំនងនេះ រវាងសហគមន៍និរទេសជនកម្ពុជានិងប្រជាជនកម្ពុជាក្នុងស្រុកមានលក្ខណៈពីរផ្ទុយគ្នា។ ទាក់ទងនឹងការប្តឹងទៅទៅតុលាការជាតិ ពួកអ្នកប្តឹង(នៅឯបរទេស) បានធ្វើដោយលក្ខណៈខុសគ្នាពីជនរងគ្រោះក្នុងស្រុក។ ពួកអ្នកប្តឹង(នៅបរទេស) មិនបានសហការនិងមិនបានទាក់ទងជាមួយសមាគមកម្ពុជាក្នុងស្រុកឡើយ។ លក្ខណៈខ្វះចន្លោះនេះគឺជាការគួរអោយសោកស្តាយ ដោយសារតែជនរងគ្រោះ នៅឯបរទេស ត្រូវកាត់ផ្តាច់ពីសភាពការណ៍ពិត នៃប្រទេសដើម កំណើតរបស់ខ្លួន។ ទំនាក់ទំនងដែលពួកជនភៀសខ្លួនអាចផ្សារភ្ជាប់ជាមួយប្រជាជនក្នុងស្រុក គឺមានលក្ខណៈជាបុគ្គលប៉ុណ្ណោះ ប៉ុន្តែមិនដែលបានធ្វើឡើងជុំគ្នា ជាផ្លូវការ ដើម្បីស្វែងរកយុត្តិធម៌ឡើយ។

ក៏ក្នុងបញ្ហានេះដែរ នៅឆ្នាំ ២០០៦ សមាគមជនរងគ្រោះពីរ នៅប្រទេសបារាំង ក៏បានបើកទីស្នាក់ការ នៅប្រទេសកម្ពុជា ដើម្បីប្រមូលភ័ស្តុតាង ពីជនរងគ្រោះក្នុងស្រុក។ តាមការវាយតំលៃជាដំបូង លទ្ធផលគឺយឺត។ សមាគមទាំងពីរនេះ ខុសគ្នាពីសមាគមក្នុងស្រុក ដែលបានធ្វើការប្រមូលភ័ស្តុតាង តាំងពីយូរយារមកហើយ។ ការងារត្រួតគ្នានេះ បញ្ជាក់ពីកង្វះការសំរបសំរួល និង ទំនាក់ទំនងគ្នា រវាងអង្គការនានា នៃសង្គមស៊ីវិល។ ហើយទំនាស់ខ្វែងមតិគ្នា ក៏កើតឡើង រវាងជនរងគ្រោះជាជនភៀសខ្លួន និង ជនរងគ្រោះ រស់នៅក្នុងស្រុក ស្តីពីដំណើរការស្វែងរកយុត្តិធម៌។ សមាគមក្នុងស្រុកខ្លះ មានការបារម្ភចំពោះការចូលរួមរបស់សមាគមមកពីក្រៅប្រទេស។ សមាគមទាំងនេះ បារម្ភថា សមាគមមកពីក្រៅប្រទេស មានសក្តានុពលខ្លាំងជាង នោះនឹងបំបាត់តួនាទី និង ការទាមទាររបស់ជនរងគ្រោះក្នុងស្រុកជាមិនខាន ពោលគឺ ផ្តល់យុត្តិធម៌ ទៅអោយសហគមន៍និរទេសជនទៅវិញ។

គឺជាការស្មុគ្រស្មាញ ពិបាកយល់ណាស់ ចំពោះទំនាក់ទំនងរវាងសហគមន៍ជនភៀសខ្លួន និង ប្រជាជនក្នុងស្រុក ដោយសារតែទំនាក់ទំនងនេះប្រកបដោយគំនិត ដែលមិនសំដែងចេញជារូបរាងពិតប្រាកដ។ ឧទាហរណ៍ ដូចជាទំនាក់ទំនង របស់ជនភៀសខ្លួនឈីលី ជាមួយប្រជាជនក្នុងស្រុក គឺមានលក្ខណៈបែកជាពីរខុសៗគ្នាអញ្ចឹង : ជនភៀសខ្លួន រងការបដិសេធពីសំណាក់ប្រជាជនក្នុងស្រុក ដែលចាត់ទុកពួកគេជាមនុស្សក្បត់ ឬ ជាជនភៀសខ្លួន "សំបូរប្រាក់កាស"។ ស្ថិតនៅចំពោះមុខការចងអាឃាតនេះ ជនភៀសខ្លួន ក៏ត្រូវរងទំងន់មួយទៀត គឺការមិនទទួលស្គាល់លក្ខន្តិកៈ របស់ ពួកគេជាជនរងគ្រោះ។ ជនភៀស

ខ្លួនទាំងនោះ ក៏កាន់តែប្រយុទ្ធខ្លាំងក្លា ថែមទៀត មានលក្ខណៈជាយុទ្ធិកៈតែម្តង[៤៦] ។ គេត្រូវរង់ចាំរហូត ដល់ផុះរឿងក្តី ពីណូដេ ទើបមានការទទួលស្គាល់លក្ខន្តិកៈជាជនរងគ្រោះ និងទើបគេផ្តល់តួនាទីស្របច្បាប់ នៅក្នុងដំណើរការស្វែងរកយុត្តិធម៌ ក្នុងនាមជាភាគីពេញសិទ្ធិ[៤៧] ។

## ខ. ការផ្តួចផ្តើមគំនិត ស្តីពីការផ្សព្វផ្សាយនិងជូនពត៌មាន

សកម្មភាពផ្សព្វផ្សាយនិងជូនពតិមាន ទាំងនៅក្នុងប្រទេសម្ចាស់ផ្ទះ ទាំងនៅក្នុងសហគមន៍និរទេសជនផ្ទាល់ គឺសំខាន់ណាស់ ដើម្បីចូលរួមក្នុងដំណើរការស្វែងរកយុត្តិធម៌ និង បង្កើនឥទ្ធិពលរបស់ខ្លួន។ ការប្រើប្រព័ន្ធផ្សព្វផ្សាយ ដោយសមាគមនានា កាន់តែមាន លក្ខណៈជាប្រព័ន្ធ និង សំបូរបែប។ បើទោះបីជា លទ្ធភាពប្រើប្រព័ន្ធផ្សព្វផ្សាយ របស់សហគមន៍និរទេសជនកម្ពុជា មានកំរិត តិចតួចក្តី ក៏សហគមន៍នេះបានខិតខំបង្កើនការផ្សព្វផ្សាយតាមប្រព័ន្ធនេះដែរ ដោយចូលរួមក្នុងនាទីវិទ្យុ ឬ ធ្វើការសំដែងជា សាធារណៈ បោះពុម្ពផ្សាយទស្សនាវដ្តី ជាដើម ។ល ។

*ការផ្សព្វផ្សាយដល់សាធារណៈ*

ដើម្បីផ្សព្វផ្សាយដល់សាធារណជន ស្តីពីដំណើរការស្វែងរកយុត្តិធម៌ ក្រោយពីអំពើប្រល័យពូជសាសន៍នោះ សមាគមនានា ដែលត្រូវសំភាសន៍ បានរៀបចំព្រឹត្តិការណ៍ជាច្រើនប្រភេទ មានដូចជា សន្និសីទ ដែលមានឥស្សរជនល្បីៗចូលរួម ពិធីបុណ្យរំលឹកអំពើប្រល័យពូជសាសន៍ បោះពុម្ពសៀវភៅស្តីពីភស្តុតាង ជាដើម។ តាមការសង្កេត ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាលធំៗ ដូចជា សហព័ន្ធអន្តជាតិនៃសិទ្ធិមនុស្ស ឬ អង្គការលើកលែងទោសអន្តរជាតិ ក្នុងដំណើរការស្វែងរកយុត្តិធម៌ គឺកាន់តែមានច្រើនឡើងៗ។ ការទំនុកបំរុងនេះ បង្កលក្ខណៈងាយស្រួល ដល់ការផ្សព្វផ្សាយអំពីគំនិតផ្តួចផ្តើមរបស់ជនរងគ្រោះ ដែលនិរទេសខ្លួន។

ជាពិសេស ការរីកចំរើននៃប្រព័ន្ធផ្សព្វផ្សាយកម្ពុជា នៅក្នុងបណ្តាប្រទេសជាម្ចាស់ផ្ទះ បានធ្វើអោយប្រព័ន្ធផ្សព្វផ្សាយនេះក្លាយទៅជាឧបករណ៍ដ៏សំខាន់ ក្នុងការជូនពតិមាន ដល់សមាជិកនៃសហគមន៍និរទេសជន ស្តីពីបច្ចុប្បន្នភាពនយោបាយ នៅប្រទេសកម្ពុជា។ ចាប់តាំងពីការមកដល់ នៃជនភៀសខ្លួន ប្រព័ន្ធផ្សព្វផ្សាយ ក៏ត្រូវបានបង្កើតឡើងដែរ។ ដំបូង គឺមានតិចទេមានត្រឹមតែព្រឹត្តិប័ត្រពតិមានប៉ុណ្ណោះ ប៉ុន្តែ ក្រោយមក ក៏មានច្រើន និង មានលក្ខណៈវិជ្ជាជីវៈផង ដូចជា ទស្សនាវដ្តីវិភាគនយោបាយ និង នាទីផ្សាយតាមវិទ្យុ ប្រកបដោយគុណភាព[៤៨] ។

---

[៤៦] ហ្វាន់នី ជេតលិកគី ដូចលើកឡើងពីខាងដើម ទំព័រ ៦០។

[៤៧] ហ្វាន់នី ជេតលិកគី ដូចលើកឡើងពីខាងដើម ទំព័រ ៦២។

[៤៨] ក្នុងចំណោមនេះ គឺមានកាសែតចតុមុខ ទស្សនាវដ្តី "លំហអាស៊ី" និង "សំណោរអង្គរ" នាទីផ្សាយ នៃវិទ្យុបារាំងអន្តរជាតិ ផ្នែកភាសាខ្មែរ ប្រព័ន្ធផ្សព្វផ្សាយខ្មែរ នៅប្រទេសបារាំង សំណោរអង្គរ លេខ ៣ វិច្ឆិកា ២០០៣។

ប្រការដែលគួរកត់សំគាល់នោះ គឺមានសមាជិកខ្លះ នៃសហគមន៏ជនភៀសខ្លួនកម្ពុជា បានជំរុញលទ្ធិប្រជាធិបតេយ្យ នៅក្នុងប្រទេសកំណើតរបស់ខ្លួន ដោយចូលប្រឡូកក្នុងឆាកនយោបាយទៀតផង។ អញ្ចឹងហើយ គេសង្កេតឃើញថា មាននិហរណកម្ម នៃទំនាស់នយោបាយ នៅប្រទេសកម្ពុជា ចូលមកក្នុងប្រទេសជាម្ចាស់ផ្ទះ ប៉ុន្តែនិហរណកម្មនេះ ស្ថិតនៅត្រឹមតែជាពាក្យសំដីទេ[៤៩]។ ឧទាហរណ៍ដូចជា មេដឹកនាំនយោបាយសម រង្ស៊ី ដែលជាអ្នកប្រឆាំងធំជាងគេ ទៅនឹងរបបភ្នំពេញ បានធ្វើសកម្មភាព មិនត្រឹមតែនៅក្នុងប្រទេសទេ ថែមទាំងឃោសនាអូសទាញសមាជិកនៃសហគមន៏និរទេសជនកម្ពុជានៅឯបរទេសទៀតផង។ ដូច្នេះ ការប្រើមធ្យោបាយផ្សព្វផ្សាយ និង បច្ចេកទេស បំរើអោយការជូនពតិមាន គឺមានសារៈសំខាន់ណាស់។

ទន្ទឹមនេះដែរ ចំណងទំនាក់ទំនងជាមួយសហគមន៏និរទេសជនដទៃទៀត ដែលរងគ្រោះដោយអំពើសម្លាប់រង្គៀលនោះក៏ត្រូវបាន បង្កើតឡើង និង ឈានដល់ការធ្វើសន្និសីទ ‹‹ អន្តរ-សហគមន៏ ›› ទៀតផង។ តាមពិតទៅ សហគមន៏ទាំងនោះ សុទ្ធតែប្រឈមមុខនឹងបញ្ហាដូចៗគ្នា ដោយសារតែត្រូវរងអំពើឃោរឃៅដូចៗគ្នា។ លោកហ្សង់ ហាតហ្វែល បានគូសបញ្ជាក់អំពីភាពដូចគ្នា ដោយថ្លែងថា : *‹‹ពួកពេជ្ឈឃាតប្រល័យពូជសាសន៏ គ្មានទទួលខុសត្រូវបន្តិចណាសោះ។ ពួកវាបានប្រព្រឹត្តអំពើខុសឆ្គងដ៏ធំធេង ហើយ ពួកវាបែរជាមិនទទួលស្គាល់ទៅវិញ។ ម្យ៉ាងទៀត ក៏មានភាពដូចគ្នាជាខ្លាំង រវាងជនរស់រានទានាពីអំពើ ប្រល័យពូជសាសន៏ដែរ : រូបភាពមួយ នៃពិរុទ្ធភាព ដោយសារតែបាននៅរស់រានមានជីវិត ការលំបាកក្នុងការនិយាយថ្លែង ប្រាប់គេ ការបារម្ភថាគេមិនជឿខ្លួន។ ម្យ៉ាងទៀត គឺបែរទៅជាពួកពេជ្ឈឃាត ក្លាយជាជនរងគ្រោះត្រូវគេផ្ដិបចោល និង គ្មានរង្គើអ្វីសោះ។ ចំណែកជនរងគ្រោះវិញ បែរជាក្លាយជាពិរុទ្ធជនទៅវិញ។ សូមអានសៀវភៅលោកព្រីម៉ូ ឡឺវី, សូអាស់ ដឺ ក្លូដ ឡង់ស្មាន់ ទស្សនាខ្សែភាពយន្ត របស់លោករិទ្ធីប៉ាន់ ឬ ក៏សៀវភៅផ្ទាល់របស់ខ្ញុំចុះ លោកអ្នកនឹងឃើញថា ពិតជាភាពដូចគ្នា ខ្លាំងណាស់។ ››*[៥០] លើសពីនេះទៀត សមាជិកមួយរូប នៃសមាគមជនភៀសខ្លួនកម្ពុជា នៅប្រទេសបារាំង ក៏បានទំនាក់ទំនង យ៉ាងស្និតរមួត រវាងសមាគមរបស់គាត់ និង សហគមន៏ជនភៀសខ្លួនអាម៉េនី វ៉ាន់ដា និង ជ្វីហដែរ[៥១]។

ដោយឡែក សមាគមជនរងគ្រោះវ៉ាន់ដា ក៏បានអះអាងពីទំនាក់ទំនងអន្តរ-សហគមន៏ របស់សមាគមនេះដែរ ដោយលើកឡើងអំពីចំណងទាក់ទង ជាមួយជនរងគ្រោះនៅសូអាស់និងនៅប្រទេសអាម៉េនី : *‹‹ (...) ឧទាហរណ៏ យើងបានចូលរួម*

---

[៤៩] ស៊ីម៉ុន បារុច *ជនភៀសខ្លួនកម្ពុជា នៅប្រទេសបារាំង និង កូនចៅ ប្រវត្តិសាស្ត្រ ២០០០ ឆ្នាំ* ក្រោមការដឹកនាំរបស់ លីសា អង់តឺប៊ី-យេមីនី, វីលីយ៉ាំ ប៊ែតូមីញែ និង ហ្កប្រ៊ីយេល សេហ្វ័រ សារពតិមានសាកលវិទ្យាល័យរ៉ែន ២០០៥ ទំព័រ ៤០១។

[៥០] ហ្វីលីព ម៉ង់ហ្សូ, ហ្សង់-ហ្វីលីព រ៉ុនូអា, អ៊ីសាបែល សាំងសង់ ព្រលឹងនៃសាកសព បទសំភាសន៏ ជាមួយលោក ហ្សង់ ហាតហ្វែល និង រិទ្ធិ ប៉ាន់ ទស្សនាវដ្ដីវ៉ាកាម លេខ ២៧ ២០០៤។

[៥១] សមាជិកនោះ បានយោងដល់សន្និសីទ ដែលរៀបចំដោយសហភាព ទទួលស្គាល់អំពើប្រល័យពូជសាសន៏ មានទីស្នាក់ការនៅក្រុងលីយ៉ុង។ សហភាពនេះ មានសមាជិកជាច្រើន ដូចជា សមាគមវ៉ាន់ដា ឈីលី កម្ពុជា អាម៉េនី ជ្វីហ។

*ក្នុងសិក្ខាសាលា ស្តីពីផលអវិជ្ជមាន ដែលរៀបចំឡើង ដោយសមាគម HAVEL ជាសមាគមជនជ្វីហ និង អារម៉េនី។ ការផ្លាស់ប្តូរមតិ ដែលយើងអាចធ្វើជាមួយពួកជ្វីហ (...) គឺសុទ្ធតែជាសមាគមផ្លូវការល្បីៗ (មជ្ឈមណ្ឌល ឯកសារជ្វីហ សម័យថ្មី នៅសារមន្ទីរសូអាស់ នាក្រុងប៉ារីស), ហាចូមែ ជាសមាគមយុវជនជ្វីហ ដែលរៀបចំដំណើរទៅប្រទេស រ៉ាន់ដា និង អ៊ីស្រាអែល មជ្ឈមណ្ឌលស៊ីម៉ុន វីសង់តាល់...។ ការផ្លាស់ប្តូរមតិទាំងនេះ អាចអោយយើងប្រៀបធៀប បទពិសោធន៍របស់យើង។ បទពិសោធន៍របស់ពួកជ្វីហ មានប្រយោជន៍ចំពោះពួករ៉ាន់ដា អំពីរបៀបរំលឹកវិញ្ញាណក្ខន្ធ... »។* ហេតុដូច្នេះហើយ ទើបនៅក្នុងសហគមន៍ជនភៀសខ្លួន គេបានបង្កើតឡើងនូវវេទិកាមួយ របស់ជនរងគ្រោះដោយអំពើព្រៃផ្សៃ ដូចៗគ្នា។ ការផ្លាស់ប្តូរមតិគ្នានេះ អាចអោយគេរៀនសូត្រពីគ្នាទៅវិញទៅមក និង អាចអោយគេរិះរកមធ្យោបាយ ធ្វើសកម្មភាពជាបន្តបន្ទាប់ឥតឈប់ឈរ។ ក៏ដូចនេះដែរការស្រាវជ្រាវដែលឈរលើទស្សនៈរួមក៏ត្រូវបានអនុវត្តដែរ។ ដូច្នេះ ចលនានេះក៏បញ្ជាក់ពី ការរីកចំរើន នៃចំណេះធ្វើ និង វិធីសាស្ត្រពិសេសៗ របស់ជនរងគ្រោះដែរ។

*ការផ្សព្វផ្សាយដល់អង្គការអន្តរជាតិ*

ពួកជនរងគ្រោះ នៃសហគមន៍និរទេសជនកម្ពុជា ធ្វើការផ្សព្វផ្សាយ ដាច់ដោយឡែក ជាលក្ខណៈបុគ្គល ចំពោះអង្គការអន្តរជាតិ គឺមិនមែនក្នុងនាមរបស់សមាគមជនរងគ្រោះឡើយ។ ឧទាហរណ៍ លោកស្រីមេម៉ាយ អតីតប្រធានរដ្ឋសភា អ៊ុង ប៊ុនហោ បានថ្លែងសុន្ទរកថា ក្នុងឱកាសចូលកាន់តំណែង របស់ព្រះរាជអាជ្ញា តុលាការព្រហ្មទណ្ឌអន្តរជាតិ ក្នុងនាមជាជនរងគ្រោះម្នាក់ មិនមែនក្នុងនាមគាត់ ជាប្រធានសមាគមឡើយ។ ក៏ដូចគ្នានេះដែរ សមាជិកខ្លះ នៃសមាគមជនរងគ្រោះ ត្រូវបានពិគ្រោះ យោបល់ ក្នុងនាមជាអ្នកជំនាញការ ស្តីពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ ក្នុងនាមជាបុគ្គលបង្អែក ស្តីពីឧក្រិដ្ឋកម្ម នៅប្រទេស កម្ពុជា ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ សភាអឺរ៉ុប សហប្រជាជាតិ (មានជាអាទិ នៅក្នុងឱកាសចរចា ស្តីពីបែបបទ នៃការបង្កើតតុលាការអន្តរជាតិ ដើម្បីកាត់ទោសពួកឧក្រិដ្ឋជនខ្មែរក្រហម)។ កិច្ចពិគ្រោះយោបល់ទាំងនេះ គឺតែងតែប្រព្រឹត្ត ទៅជាលក្ខណៈបុគ្គលជានិច្ច ដោយឈរលើមូលដ្ឋាននៃបទពិសោធន៍របស់ពួកជំនាញការទាំងនេះឯង គឺមិនមែនឈរលើ មូលដ្ឋានដែលថាពួកគេជាសមាជិក នៃសមាគមជនរងគ្រោះណាមួយឡើយ។

*ការផ្សព្វផ្សាយដល់បណ្តាប្រទេសជាម្ចាស់ផ្ទះ*

តាមរយៈសមាគមយុត្តិធមិសំរាប់ប្រទេសកម្ពុជា ជនរងគ្រោះខ្មែរនៅប្រទេសបារាំង ខិតខំផ្សព្វផ្សាយ ជំរាបដល់អាជ្ញាធរ បារាំង ស្តីពីការងារកាត់ទោសពួកអតីតមេដឹកនាំខ្មែរក្រហម តាមរយៈសមាជិកសភា។ សមាជិកសភាទាំងនេះ មានអ្នកនាំ ពាក្យមួយរូប នៅព្រឹទ្ធសភា ឈ្មោះ កាតឺរីន តាស្កា។ សមាគមជនរងគ្រោះទាំងនេះ បានថ្លែងមតិជាច្រើនដង ជូនអាជ្ញាធរ បារាំង ដោយជូនកាល បានអញ្ជើញអាជ្ញាធរបារាំង មកចូលរួមក្នុងសិក្ខាសាលា ឬ ពិធីរំលឹកព្រឹត្តិការណ៍ប្រល័យពូជសាសន៍ ជាដើម ការគាំទ្រចំពោះសហគមន៍ខ្មែរ នៅមានលក្ខណៈជាផ្លូវចិត្ត និង ជានិមិត្តរូបប៉ុណ្ណោះ ដូចជាសេចក្តីថ្លែងការណ៍ថ្មីៗនេះ

របស់រដ្ឋាភិបាលបារាំង គាំទ្រដំណើរការស្វែងរកយុត្តិធម៌ និង ការតស៊ូប្រឆាំងនិទណ្ឌភាព[៥២] ។ បើទោះជាយ៉ាងណាក្តី គេគួរកត់សំគាល់ថា តាមការជាក់ស្តែងនោះ ប្រទេសបារាំង គាំទ្រដាច់ដោយឡែក ចំពោះប្រជាជនកម្ពុជាក្នុងស្រុក ហើយប្រការនេះគឺមានលក្ខណៈសំខាន់ជាងដំណើរការស្វែងរកយុត្តិធម៌[៥៣] ទៅទៀត។ ប្រទេសបែលហ្សិក បានគាំទ្រផ្លូវចិត្ត និង ជានិមិត្តរូបចំពោះសហគមន៍និរទេសជនកម្ពុជាដែរ[៥៤] ។

## គ. តួនាទីគន្លឹះ នៃស្រុករមនុស្សជំនាន់ទី២ នៅក្នុងដំណើរការស្វែងរកការពិត

នៅក្នុងផ្ទៃក្នុងសហគមន៍និរទេសជន តួនាទីរបស់ស្រករមនុស្សជំនាន់ទីពីរ ក៏ត្រូវបានទទួលស្គាល់កាន់តែខ្លាំងឡើងៗ នៅក្នុងមជ្ឈដ្ឋានគ្រួសារ។ តាមពិតទៅ ស្ថានការណ៍បានវិវត្តបញ្ច្រាសទិសទៅវិញ ពីព្រោះថា ដោយសារខ្លួនចេះភាសាបារាំងជ្រៅជ្រះនោះ យុវជនទាំងនោះក៏ជួយឪពុកម្តាយរបស់ពួកគេ ក្នុងការគ្រប់គ្រងរដ្ឋបាលប្រចាំថ្ងៃ[៥៥] ។ ជាទូទៅពួកកុមារដែលមានឪពុកម្តាយ ជាស្រទាប់បញ្ញវ័ន្តនោះ ពួកគេរៀនសូត្រដោយគ្មានបញ្ហា ហើយចេះភាសាបារាំងយ៉ាងស្ទាត់ ហើយរកការងារធ្វើបានល្អជាង ការងាររបស់ឪពុកម្តាយពួកគេទៅទៀត។ ដោយរក្សាទំនាក់ទំនងជាប់ជាមួយប្រទេសកម្ពុជា យុវជនទាំងនោះបានយកចិត្តទុកដាក់ជាខ្លាំងចំពោះប្រទេសកម្ពុជា និងប្រវត្តិសាស្ត្រនៃប្រទេសនេះ។ ពួកគេរៀនភាសាខ្មែរឡើងវិញ ពីព្រោះអ្នកខ្លះខានប្រើភាសាជាតិឯងតាំងពីវ័យជំទង់មកម្ល៉េះ។ តាមរបៀបនេះ យុវជនខ្លះ បានចូលជាសមាជិកសមាគមនានា ហើយផ្តួចផ្តើមគំនិតគាំទ្រប្រទេសកំណើតរបស់ខ្លួន[៥៦] ។ ពួកគេបានបង្កើតបណ្តាញយុវជនបារាំង ដើមកំណើតខ្មែរ[៥៧] ទន្ទឹមនេះ ក៏ធ្វើសកម្មភាពបង្កើតវេទិកាផ្លាស់ប្តូរមតិ និងត្រិះរិះពិចារណាអំពីការស្វែងរកយុត្តិធម៌។ ការប្រមូលផ្តុំគ្នាកាន់តែច្រើនឡើងៗ ដោយពួកគេ ផ្តួចផ្តើមគំនិតរៀបចំពិធីបុណ្យរំលឹកអំពើប្រល័យពូជសាសន៍កាលពីឆ្នាំ ២០០៥។ ពិធីនេះប្រព្រឹត្តទៅ ដោយមានធ្វើសន្និសីទ ដើម្បីផ្សព្វផ្សាយដល់មហាជន អំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអំពីការប្រយុទ្ធប្រឆាំងនិទណ្ឌភាព[៥៨] ។ ទន្ទឹមនេះដែរ ក៏គួរ រំលឹកថា សហភាពជនរងគ្រោះ ដោយពួកខ្មែរក្រហម ក៏រួមមានសមាគមនិស្សិត

---

[៥២] ‹‹ *គ្មានការតស៊ូប្រឆាំងនិទណ្ឌភាព ដើម្បីជាការគោរពដល់អត្តសញ្ញាណ និង ប្រវត្តិសាស្ត្រខ្មែរ នោះពិតជាគ្មានការបង្រួបបង្រួមជាតិ យូរអង្វែងឡើយ* ›› ។ សង្កាថារបស់លោក ដូមិនិច ដឺ វីលប៉ាំង ក្នុងឱកាសភោជនាហារ ជូនជាកិត្តិយស ដល់ព្រះករុណា នរោត្តមសីហមុនី មហាក្សត្រនៃប្រទេសកម្ពុជា នាថ្ងៃ ២១ វិច្ឆិកា ២០០៦ នៅក្រុង ប៉ារីស។

[៥៣] ជាឧទាហរណ៍ មជ្ឈមណ្ឌលសោតទស្សន៍ បូផាណា ដែលផ្តល់ហិរញ្ញវត្ថុ ដោយរដ្ឋាភិបាលបារាំង និង បង្កើតឡើង ដោយអ្នកថតភាពយន្ត រិទ្ធី ប៉ាន់ មិនរក្សាតែឯកសារ ជំនាន់ប្រល័យពូជសាសន៍ទេ គឺមានឯកសារពីវប្បធម៌ខ្មែរទូទៅ។

[៥៤] ជាការជូនពតិមាន ប្រទេសបែលហ្សិក គាំទ្រការកាត់ទោសពួកមេដឹកនាំខ្មែរក្រហមដែរ។ *វិភាគទានបែលហ្សិក ចំពោះតុលាការខ្មែរក្រហម ប្រកាសពតិមានរបស់ក្រសួងការបរទេស ថ្ងៃ ៥ មេសា ២០០៥។*

[៥៥] ស្តេហ្វានី ណាន់ ដូចបានលើកឡើងខាងដើម ទំព័រ ១៥៩។

[៥៦] ស៊ីម៉ុន បារូច *ទេសន្តរប្រវេសន៍ និង ជីវភាព នៅប្រទេសបារាំង របស់ប្រជាជនដើមកំណើតខ្មែរ, ឡាវ, វៀតណាម និង កូនចៅរបស់ពួកគេ* ទស្សនាវដ្តី ស្ពានចម្លង លេខ ១៤ រដូវរងា ១៩៩៧ ទំព័រ ១៦៥។

[៥៧] http://www.lesjeuneskhmers.com

[៥៨] *១៧ មេសា ២០០៥ ទិវារំលឹកអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តឡើង ក្នុងរបបខ្មែរក្រហម* , សំណេរអង្គរ លេខ ៨ មេសា ២០០៥។

ជាសមាជិកស្ថាបនិកដែរ។ ក្រោយពីបញ្ចប់ ការសិក្សា និស្សិតខ្លះ ដែលប្រកប ដោយសទ្ធុះចិត្តខ្លាំងក្លានោះបានធ្វើដំណើរទៅប្រទេសកម្ពុជា។ និស្សិតដែលមានជំនាញខ្ពស់ ទាំងនេះ ច្រើនតែចូលរួម ក្នុងការងារអភិវឌ្ឍ និង សហប្រតិបត្តិការ[៥៩] ។ គួរកត់សំគាល់ថា សមានចិត្តចំពោះប្រទេសកម្ពុជារបស់យុវជនខ្មែររស់នៅសហរដ្ឋអាមេរិក មិនមានសទ្ធុះខ្លាំងក្លាទេ។ គួររំលឹកថា ពួកជនភៀសខ្លួនខ្មែរ ភាគច្រើនដែលរស់នៅសហរដ្ឋអាមេរិក គឺជាគ្រួសារទាហាន ឬ កសិករ។ ដូច្នេះ បាតុភូត នៃការប្រមូលផ្តុំនេះ គឺអាស្រ័យទៅនឹងកិរិតវប្បធមិរបស់ជនរងគ្រោះផង និង កិរិតវប្បធមិរបស់កូនៗ របស់ពួកគាត់ផង។ ក៏ប៉ុន្តែក៏មាន គំនិតផ្តួចផ្តើម នៅសហរដ្ឋអាមេរិកដែរ ដូចជាការបញ្ចាំងខ្សែភាពយន្តជាដើម ប៉ុន្តែ ជាលក្ខណ:បុគ្គល[៦០] ប៉ុណ្ណោះ។

ការចូលរួមរបស់កូនៗ នៃជនរងគ្រោះខ្មែរ ក៏មានលក្ខណ:ដូចគ្នានឹងការចូលរួមរបស់ជនភៀសខ្លួនឈីលីដែរ។ ‹‹ *គំនិតរំដោះអំពីរឿងក្តីពីណូជេ ក្នុងសតិអារម្មណ៍របស់ជនភៀសខ្លួនឈិលីប្រព្រឹត្តទៅតាមគ្រួសារនានា ហើយក្រោយមក ក៏មានការផ្ទេរសតិអារម្មណ៍នេះឡើង។ ជួនកាលតាមរយ:ប្រព័ន្ធផ្សព្វផ្សាយ កុមារទាំងនោះបានឃើញចម្លើយ ជាសាក្សីរបស់ឪពុកម្តាយ របស់ពួកគេ។ ដោយឡែក ការជជែកពិភាក្សាជាច្រើន នៅតាមគ្រួសារនានា ស្តីពីអំពើប្រល័យពូជសាសន៍ ក៏ធ្វើអោយកុមារទាំងនោះ ចាប់អារម្មណ៍ ចំពោះប្រវត្តិរបស់ឪពុកម្តាយរបស់ពួកគេដែរ។ ជាដំបូង ការចូលរួម របស់យុវជនទាំងនោះ គឺមកពីពួកគេស្រឡាញ់ អាណិត ឪពុកម្តាយ របស់ពួកគេ ដែលជាភាគីពិតៗ ក្នុងរឿងក្តី។ ការចូលរួម របស់យុវជននេះ ក៏បានរីកចំរើនយ៉ាងឆាប់រហ័ស ដោយសារបណ្តាញកូនរបស់ជនភៀសខ្លួន ដែលមានពីរវាង ១៥ នាក់ ទៅ ៤០ នាក់ តែក្នុងរយ:ពេល ១៧ ខែប៉ុណ្ណោះ។ ដោយមិនយល់ ឬ ឆ្ងល់ចំពោះរឿមច្បងរបស់ពួកគេ ពួកគេចេះតែប្រជុំគ្នា ប្រមូលផ្តុំគ្នា ហើយក្លាយជាកម្លាំងស្វ័តមួយឡើង។ ការប្រមូលផ្តុំគ្នា ឬ ចងជាចង្កោមនេះ អាចអោយពួកយុវជនទាំងនោះ ទទួលបានមរតក របស់ពួកខ្លួនពិតៗតែម្តង[៦១]* ››។ ដូច្នេះ រឿងក្តីពីណូជេ បានជំរុញអោយមានចលនា ដ៏ខ្លាំងក្លា នៃអត្តសញ្ញាណកម្ម និង ការចូលរួមជាយុទ្ធិក: នៅក្នុងផ្ទៃក្នុង របស់យុវជន។

## ៤. សហគមន៍និរទេសជន គឺជាសក្តានុពលមួយ ដែលត្រូវពង្រីកបន្ថែម

តាមរយ:ជំហានដំបូងៗ របស់សហគមន៍និរទេសជន ដែលជាភាគីថ្មីមួយ នៅលើឆាកតុលាការអន្តរជាតិ គេត្រូវតែមើលអោយឃើញ នូវសក្តានុភាពជាច្រើន របស់សហគមន៍នេះ។ តុលាការអន្តរជាតិ បានជំរុញអោយមានការភ្ញាក់រលឹកមនសិការ របស់

[៥៩] ស៊ីម៉ុន បារុច *ជនភៀសខ្លួនកម្ពុជា នៅប្រទេសបារាំង និង កូនចៅ ប្រវត្តិសាស្ត្រ ២000 ឆ្នាំ* ក្រោមការដឹកនាំរបស់ លីសា អង់គីប៊ី-យេមីនី, វីលីយ៉ាំ ប៉ែតូមីញ៉ែ និង ហ្កប្រីយេល សេហ្វ័រ សារពតិមានសាកលវិទ្យាល័យរ៉ែន ២០០៥ ទំព័រ ៤០៦។

[៦០] ជាឧទាហរណ៍ ខ្សែភាពយន្តរបស់ សុជាតា ពៅ ‹‹ New Year Baby ›› ដែលបានទទួលរង្វាន់ជាច្រើនគួរត្រូវបន្ត ដោយគំរោងប្រមូលភស្តុតាង នៅក្នុងផ្ទៃសហគមន៍និរទេសជន ថែមទៀត។ http://www.newyearbaby.net/site/c.grKNIWPHIsE/b.672275/k.CBF1/Home.htm

[៦១] ហ្វាន់នី ជេតលិកគី ដូចដែលលើកឡើងខាងលើ ទំព័រ ៧២។

សហគមន៍និរទេសជន។ តុលាការនេះបានផ្តល់លទ្ធភាពដ៏ធំធេងដល់សហគមន៍និរទេសជន ក្នុងការស្វែងរកយុត្តិធម៌ ជាពិសេស គឺនៅពេលដែលតុលាការ នៅក្នុងប្រទេសកំណើតទន់ខ្សោយ ឬ គ្មានឆន្ទៈ។ ក្រៅពីនេះទៀត សហគមន៍និរទេសជនក៏មានតួនាទីដ៏សំខាន់ក្នុងការផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅទ្វីបអឺរ៉ុបនោះ បានបង្កអោយមានការចាប់អារម្មណ៍ជាខ្លាំង ទាំងនៅក្នុងផ្ទៃសហគមន៍ផ្ទាល់ ទាំងចំពោះប្រជាជនបែលហ្សិក អង់គ្លេស អ៊ីតាលី។ល។ ញត្តិ សកម្មភាពបញ្ចុះបញ្ចូល និង សកម្មភាពដទៃៗទៀត ដ៏មានប្រសិទ្ធភាព សុទ្ធតែទទួលបានការគាំទ្រពីសំណាក់សង្គមស៊ីវិល ក្នុងស្រុក និង អង្គការក្រៅរដ្ឋាភិបាលសំខាន់ៗ។

ប៉ុន្តែទោះជាយ៉ាងដូច្នេះក្តី ក៏ទិដ្ឋភាពខ្លះៗ ត្រូវតែពិចារណាឡើងវិញ ដើម្បីបង្កើនឥទ្ធិពល និង ប្រសិទ្ធភាព របស់វាថែមទៀត :

- ប្រឹងប្រែងធ្វើការផ្សព្វផ្សាយ ដើម្បីកំចាត់ចោលភាពឯកោរបស់សហគមន៍និរទេសជន។
- ធ្វើអោយគំនិតផ្តួចផ្តើមកាន់តែសំបូរបែប និង កាន់តែប្លែកៗទៀត : វិភាគទានលើផ្នែកតុលាការ តាមរយៈការផ្តល់អនុសាសន៍ និង ការផ្សព្វផ្សាយ។
- ត្រូវមានធនធានសំភារៈ មនុស្ស និង ហិរញ្ញវត្ថុ ដើម្បីធានា ដល់ការប្រព្រឹត្តទៅ និង ការគ្រប់គ្រងសមាគមនានា។

## តស៊ូប្រឆាំងនឹងភាពឯកោ របស់សហគមន៍និរទេសជន

មានកត្តាជាច្រើន ដែលខ័ណ្ឌ ឬ ក៏ឯកោសហគមន៍និរទេសជន ដែលជាហេតុធ្វើអោយគំនិតផ្តួចផ្តើមរបស់សហគមន៍ទាំងនេះអន់ថយថាមពល និង ឥទ្ធិពល។ ដូច្នេះ ត្រូវតែបង្កើនផ្នែកទំនាក់ទំនង ដោយបង្កើតវេទិកាពិភាក្សាតាមក៏រិតបី ដូចតទៅ :

*កិច្ចពិភាក្សា រវាងជនភៀសខ្លួននានា*

ជាទូទៅ កិច្ចពិភាក្សានេះ កាន់តែសក្តិសិទ្ធ ដរាបណា សហគមន៍ទាំងនេះ មានបទពិសោធន៍ក្នុងឆាកជីវិត ដូចៗគ្នា និង ត្រូវធ្វើសមាហរណកម្ម នៅក្នុងប្រទេសម្ចាស់ផ្ទះ។ គឺដូចគ្នានេះដែរ សហគមន៍ទាំងនោះ ត្រូវប្រឈមមុខនឹងដំណើរការកាន់មរណៈទុក្ខ និង បញ្ហាបង្រួបបង្រួមទៀតផង។ ដោយត្រូវបង្ខំអោយភៀសខ្លួន ដើម្បីគេចពីអំពើយង់ឃ្នងនៅក្នុងប្រទេសដើមកំណើត សហគមន៍រស់នៅទ្វេគ្រោះដូចៗគ្នា និងទទួលរងពិរុទ្ធភាពដូចៗគ្នា។ ការទាមទារ របស់ពួកគេត្រូវបំបាត់យ៉ាងកំរោល : យុត្តិធម៌ កាតព្វកិច្ចនៃមនសិការ កាតព្វកិច្ចសីលធម៌ដែលត្រូវនាំពាក្យរបស់ប្រជាជនក្នុងស្រុក ទៅផ្សាយនៅក្រៅប្រទេស ។ល។ សហគមន៍ទាំងនោះ តែងរៀបចំព្រឹត្តិការណ៍ដូចៗគ្នា ដូចជាសិក្ខាសាលា ពិធីរំលឹកផ្សេងៗ ឬ ក៏វេទិកាផ្សាយពតិមាន។ ការផ្លាស់ ប្តូរមតិអន្តរ-សហគមន៍និរទេសជន អាចធ្វើអោយជនរងគ្រោះ ជាជនភៀសខ្លួន បានដឹងថា ពួកខ្លួនមិនមែនជាករណីតែមួយ គត់ទេ គឺមានប្រជាជនដទៃទៀត ត្រូវរងអំពើឃោរឃៅ ដូចពួកខ្លួនដែរ។ ជនរងគ្រោះទាំងនោះក៏លែងយល់ថាពួកខ្លួនត្រូវ ឯកោ ហើយក៏ទទួលស្គាល់ឋានៈខ្លួន ជាជនរងគ្រោះ។ ប៉ុន្តែប្រការនេះ មិនមែនងាយស្រួលប៉ុន្មានទេ

ដោយសារតែពុំមាន សេចក្តីសំរេចរបស់តុលាការ។ ដោយឡែក ជនរងគ្រោះសួរអាស់ ក៏ព្រាប់តាមសហគមន៍ជនភៀសខ្លួនផ្សេងៗទៀតដែរ ដូចជា ក្នុងយន្តការកាន់មរណៈទុក្ខ ពិធីរំលឹកផ្សេងៗ និង ការស្វែងរកយុត្តិធម៌។ ជាការពិតហើយថា សហគមន៍និរទេសជនទាំងអស់ មិនមែនសុទ្ធតែមានមធ្យោបាយស្មើៗគ្នានោះទេ ប៉ុន្តែបើពួកគេពិភាក្សាគ្នានោះពួកគេ នឹងរកឃើញលទ្ធភាពដ៏ច្រើន បង្កើតបាន ជាកម្លាំងមួយដ៏ខ្លាំងក្លា និង ទទួលបានចំណេះដឹងផ្នែកច្បាប់ជាគុណប្រយោជន៍ ដល់ សហគមន៍និរទេសជន។ វិធីសាស្ត្រនេះ មានប្រយោជន៍ចំពោះសហគមន៍ណាស់ ជាពិសេសចំពោះសហគមន៍ជនភៀសខ្លួន ដែលទើបមកដល់ថ្មី ហើយត្រូវវង្វេងវង្វាន់ មិនដឹងទិសដៅ នៅក្នុងប្រទេសម្ចាស់ផ្ទះ។

*កិច្ចពិភាក្សា នៅក្នុងផ្ទៃសហគមន៍តែមួយ នៅតាមប្រទេសនានា*

ជារឿយៗ ដោយត្រូវជាប់គាំងក្នុងសហគមន៍របស់ខ្លួននោះ សមាគមជនរងគ្រោះត្រូវឯកោ គ្មានមធ្យោបាយ និងស្ទើរតែមិនដឹងថាត្រូវទាមទារពីប្រទេសជាម្ចាស់ផ្ទះផង។ ដូច្នេះ ទំនាក់ទំនងសាមគ្គីជាមួយសហគមន៍ដទៃទៀត ដែលមានកំណើតពីប្រទេសដូចគ្នា ប៉ុន្តែតាំងទីលំនៅនៅក្នុងប្រទេសដទៃទៀត គឺមានសារៈសំខាន់ណាស់ អាចនាំអោយរើបំរាស់ចេញផុតពីទីកន្លែងបិទ ជិតនេះ។ ដោយឡែក ដោយយោលទៅតាមប្រទេសជាម្ចាស់ផ្ទះ និងដោយយោលទៅតាមក៏រិត វប្បធម៌របស់ពួកខ្លួន សហគមន៍និរទេសជនមិនមានទស្សនៈដូចៗគ្នាអំពីការស្វែងរកយុត្តិធម៌ទេ ហើយក៏មិនមានមធ្យោបាយដូចៗគ្នាសំរាប់ធ្វើ សកម្មភាពដែរ។ ម៉្យាងទៀត លទ្ធភាពធ្វើការប្តឹងតាមផ្លូវច្បាប់ខុសៗគ្នា ទៅតាមច្បាប់ជាតិ នៃប្រទេសនិមួយៗ។ ដូចជានៅប្រទេសបែលហ្សិក គេមានច្បាប់ស្តីពីសិទ្ធិសាកល ដែលផ្តល់មធ្យោបាយដ៏សំបើម ក្នុងការប្តឹង។ ប៉ុន្តែ នៅប្រទេសបារាំងគ្មានច្បាប់នេះទេ។ អញ្ចឹងហើយ បានជានៅឆ្នាំ១៩៩៩ ជនភៀសខ្លួនខ្មែរនៅប្រទេសបារាំង ត្រូវទៅចូលរួមប្តឹង ជាមួយជនរងគ្រោះខ្មែររស់នៅប្រទេសបែលហ្សិក។ សារៈប្រយោជន៍ នៃការគួបកម្លាំងគ្នាបែបនេះ គឺដើម្បីផ្តល់ឱកាសអោយជនភៀសខ្លួនដែលគ្មានឱកាស ដូចនេះដែរ នៅក្នុងប្រទេសជាម្ចាស់ផ្ទះ។ ប៉ុន្តែ ការគួបកម្លាំងគ្នានេះក៏គឺដើម្បីបន្ថែមទំងន់ទាំងផ្នែកបរិមាណ និង និមិត្តរូប នៅមុខតុលាការដែរ។ ក៏ដូចគ្នានេះដែរ សហគមន៍វ៉ាន់ដារស់នៅប្រទេសបារាំងក៏បានប្រើវិធីនេះដែរក្នុងការកាត់ទោសពួកជាប់ចោទប្រល័យពូជសាសន៍ដែលប្រព្រឹត្តទៅនៅក្នុងព្រុចសែល។ ចំណែកឯសហគមន៍ឈិលីវិញ ក៏បានផ្តល់ជាគំរូដ៏ត្រចះត្រចង់អំពីសាមគ្គីភាព រវាងសហគមន៍ឈិលីនានាដែលតាំងនៅក្នុងទ្វីបអឺរ៉ុបដែរ។ ក្នុងឱកាសរឿងក្តីពីណូជេ បណ្តាញសមាគមមួយ ត្រូវបានបង្កើតឡើងដើម្បីរៀបចំក្បួនព្យុហយាត្រា បាតុកម្ម និងពិចារណារួមគ្នាអំពីវិធីផ្សេងៗដើម្បីប្តឹងទៅតុលាការ។

*កិច្ចពិភាក្សារវាងសមាគមជនរងគ្រោះ នៅឯបរទេស ជាមួយនឹងសមាគមជនរងគ្រោះ នៅក្នុងប្រទេសកំណើត*

ជនរងគ្រោះ នៅឯបរទេស និង ជនរងគ្រោះ រស់នៅក្នុងប្រទេសដើមកំណើតចំណេញច្រើនណាស់ បើពួកគេធ្វើសកម្មភាពរួមគ្នាសហការគ្នា។ សហគមន៍ជនភៀសខ្លួន អាចធ្វើជាអ្នកនាំពាក្យ របស់ជនរងគ្រោះក្នុងស្រុក មកផ្សព្វផ្សាយនៅឯបរទេស បើសិន

ជាសហគមន៏នេះ សំរបសំរួលការងារបានល្អ ពីព្រោះថា ជនរងគ្រោះក្នុងស្រុក ត្រូវចុកមាត់ ដោយរដ្ឋអំណាចមួយ ដែលមិនអត់អោនអោយមានសម្លេងប្រឆាំងដាច់ខាត។ ក្នុងករណីពាក្យបណ្តឹងដែលឈរលើមូលដ្ឋាននៃសិទ្ធិសាកលការគាំទ្រគ្រប់យ៉ាង (ភស្តុតាង កសិណសាក្សី។ល។) និង របាយការណ៏ដែលផ្តល់ដោយសង្គមស៊ីវិលនៃប្រទេសដើមកំណើត បានជួយផ្តល់លទ្ធភាពដល់ជនរងគ្រោះក្នុងស្រុកអោយគេយកចិត្តទុកដាក់និងទទួលស្គាល់ដែរ។ សម្ព័ន្ធភាពរវាងសហគមន៏នៅក្រៅប្រទេស និងសង្គមស៊ីវិលក្នុងស្រុក ក៏បង្ហាញពីភាពស្របច្បាប់ នៃការប្តឹងរកយុត្តិធម៌ដែរ។ ក្រៅពីនេះ អង្គការក្នុងស្រុក ក៏អាចផ្សាយបណ្តាក់ពតិមាន គឺផ្សាយបន្តដល់ជនរងគ្រោះក្នុងស្រុកស្តីពីសកម្មភាពនានាដែលប្រព្រឹត្តទៅនៅឯក្រៅប្រទេសដែរ។ ដូច្នេះ ការផ្លាស់ប្តូរមតិត្រូវតែធ្វើឡើង ដោយឈរលើមូលដ្ឋានបំពេញអោយគ្នាទៅវិញទៅមក ដោយធ្វើយ៉ាងណាអោយសកម្មភាពរបស់សហគមន៏និរទេសជន ផ្តល់នូវផលប្រយោជន៏ពិតៗដល់ដំណើរការស្វែងរកយុត្តិធម៌។ ប្រការនេះ អាចបណ្តាលអោយមានការកាត់ទោសពួកឧក្រិដ្ឋជន នៅឯបរទេសបាន[៦២] ឬក៏គ្រាន់តែអនុវត្តនិតិវិធីប្រមូលសក្ខីកម្ម នៅក្នុងផ្ទៃ សហគមន៏ និរទេសជន។ ការសហការដ៏ល្អនៃសហគមន៏ទាំងពីរ ត្រូវធ្វើយ៉ាងណាជៀសវាងកុំអោយមានការត្រួតការងារគ្នា។ ត្រង់នេះគឺថាសមាគមទាំងនោះអាចធ្វើសកម្មភាពនៅលើទីតាំងរបស់ខ្លួន (ឯបរទេស) ប៉ុន្តែក៏ត្រូវសហការជាមួយសមាគមក្នុងស្រុកដើម្បីជៀសវាងសកម្មភាពដូចៗគ្នា (ឧទាហរណ៏ សមាគមទាំងនោះ បែងចែកការងារតាមភូមិសាស្ត្រ ឬ បែងចែកតាម ប្រធានបទ)។ វាជាប្រការមិនសំខាន់ប៉ុន្មានទេ ចំពោះបាតុភូតដែលសមាជិកនានានៃសហគមន៏និរទេសជន រក្សាខ្ជាប់ក្នុងអារម្មណ៏ថាប្រទេសកម្ពុជាវិប្បលាស ឬ បីសាចនោះ ពីព្រោះពួកគាត់កើតរោគបាក់ស្បាតទៅហើយ។ ការសហការយ៉ាង ជិតស្និទ្ធ និងជាអចិន្ត្រៃជាមួយសមាគមក្នុងស្រុក នឹងធ្វើអោយអស់សុបិន្តអាក្រក់ ពីប្រទេសដើមកំណើត របស់ខ្លួនជាមិនខាន។ គួររំលឹកថាអសកម្មភាពរបស់ជនរងគ្រោះច្រើនតែសំអាងលើជំងឺបាក់ស្បាតដែលព្យាបាលមិនទាន់ជាសះស្បើយ។ ជាដំបូងជនរងគ្រោះទាំងនោះត្រូវសំរុះសំរួលជាមួយខ្លួនឯង និងជាមួយអត្តសញ្ញាណកម្ពុជាមុននឹងទាមទារអោយមានការសងជំងឺចិត្ត។ ការទាក់ទងជាមួយប្រជាជនក្នុងស្រុកអាចជាជំហានមួយ ក្នុងវិធីសំរបសំរួលខ្លួនផ្ទាល់។ តាមពិតជាក់ស្តែង ពួកអតីតជនភៀសខ្លួនដែលមានឱកាសវិលត្រឡប់ ទៅប្រទេសកម្ពុជាវិញ ដើម្បីស្នាក់នៅរយៈពេលខ្លី សុទ្ធតែអាច ‹‹ *កែតំរូវ សុបិន្ត និង សុបិន្តអាក្រ់ដែលពួកខ្លួនបានគិតទុកជាយូរមកហើយ ប្រៀបធៀបប្រទេសកម្ពុជា កាលសម័យដែលពួកខ្លួនធ្លាប់រស់នៅ និង ពេលដែលពួកខ្លួន បានត្រឡប់មកមើលឃើញជាថ្មី*[៦៣] ››។

---

[៦២] តាមការសង្កេត ពួកអ្នកជំនាញបានលើកឡើង ពីលទ្ធភាព ធ្វើការស៊ើបអង្កេតលើពួកជនសង្ស័យ ដែលកំពុងរស់នៅក្នុងបណ្តារដ្ឋ ដែលទទួលយកជនភៀសខ្លួនជាចំនួន ច្រើនដូចជា ប្រទេសបារាំង សហរដ្ឋអាមេរិក អូស្ត្រាលី និង កាណាដា។ របាយការណ៏របស់ក្រុមអ្នកជំនាញការ ចុះថ្ងៃ ១៦ មិនា ១៩៩៩ ទំព័រ ៣៣។

[៦៣] ស៊ីម៉ុន បារុច *ជនភៀសខ្លួនកម្ពុជា នៅប្រទេសបារាំង និង កូនចៅប្រវត្តិសាស្ត្រ ២០០០ ឆ្នាំ* ក្រោមការដឹកនាំរបស់ លីសា អង់តឺប៊ី-យេមីនី, វីលីយ៉ាំ ប៉ែតូមីញ៉ែ និង ហ្កាប្រីយេល សេហ្វ៊ែរ សារពតិមានសាកលវិទ្យាល័យរ៉ែន ២០០៥ ទំព័រ ៤០២។

## ខ. ធ្វើការផ្តួចផ្តើមគំនិតបន្ថែម

*តួនាទីដ៏សកម្ម ក្នុងវិស័យច្បាប់*

សហគមន៍និរទេសជន ត្រូវតែទាញយកចំណេញ ពីការស្នាក់នៅឯបរទេស ដើម្បីអនុវត្តផ្លូវច្បាប់ ដើម្បីតស៊ូប្រឆាំងនិទណ្ឌភាព ដោយ ប្តឹងទៅតុលាការក្នុងស្រុកផង និងទៅតុលាការអន្តរជាតិផង។ ការចូលរួមនេះ ត្រូវរួមមានភារកិច្ចផ្សេងៗ ដែលពាក់ព័ន្ធនឹងនិតិវិធី ដូចជាការប្រមូលភស្តុតាង ឬ សក្ខីភាព របស់ជនភៀសខ្លួន ការរៀបចំការត្រួតពិនិត្យផ្នែកចិត្តសាស្ត្រ ។ល។

*តួនាទីតវ៉ា និង ផ្សព្វផ្សាយ*

តួនាទីនេះ បំពេញបន្ថែមលើវិស័យច្បាប់។ ការផ្សព្វផ្សាយដែលបន្តពីសកម្មភាពផ្លូវច្បាប់ ត្រូវធ្វើចំពោះទាំងប្រទេសជាម្ចាស់ផ្ទះ ទាំងចំពោះសមាជិករបស់សហគមន៍និរទេសជន។ ការផ្សព្វផ្សាយ គឺរួមមានពតិមានស្តីពីបច្ចុប្បន្នភាពក្នុងស្រុក ដើម្បីរក្សាខ្ជាប់ទំនាក់ទំនង របស់ជនភៀសខ្លួន ជាមួយប្រទេសដើមកំណើត។ ការផ្សព្វផ្សាយនេះ ក៏រួមមានពតិមានស្តីពីដំណើរការរបស់តុលាការដែរ។ ដូច្នេះហើយ គេអាចរៀបចំពិធីជូនដំណឹង ស្តីពីដំណើរការរបស់តុលាការ (ឬ តុលាការអន្តរជាតិ ក្នុងករណីប្រទេសកម្ពុជា) ការប្រឈមមុខ និង លក្ខណៈ របស់តុលាការនេះ និង ជាពិសេសនោះ គឺដំណឹងស្តីពីតួនាទីរបស់ជនរងគ្រោះក្នុងដំណើរការស្វែងរកយុត្តិធម៌ តាមរយៈការធ្វើជាសាក្សី ឬ ការដាក់ពាក្យបណ្តឹង។ លើសពីនេះទៀត ពិធីជូនដំណឹងនេះក៏អាចអោយគេធ្វើការស្ទង់មតិ និង យល់ពីបំណងប្រាថ្នារបស់សមាជិកនិមួយៗ ដើម្បីងាយតំរង់ទិស សកម្មភាពទៅថ្ងៃអនាគត។

ម៉្យាងទៀត ការផ្សព្វផ្សាយពតិមាន ដល់ប្រជាជននៃរដ្ឋជាម្ចាស់ផ្ទះ ក៏ត្រូវធ្វើឡើង ក្រោមរូបភាពជាសន្និសីទ ដែលធ្វើឡើងនៅក្នុងសាកលវិទ្យាល័យ ឬ មជ្ឈមណ្ឌលវប្បធម៌ ដោយអញ្ជើញឥស្សរជនល្បីៗ ចូលរួមផង។ កាន់តែទូលំទូលាយ ទៅទៀតនោះ គេបង្កើតសមាគមវប្បធម៌ ដែលមានគោលដៅប្លែកៗ - រៀបចំពិធីសាធារណៈ មានដូចជា ពិធីរំលឹកព្រឹត្តិការណ៍នានា និង ការចេញផ្សាយពតិមានតាមប្រព័ន្ធផ្សព្វផ្សាយដើម្បីផ្សារភ្ជាប់ប្រជាជននៃប្រទេសជាម្ចាស់ផ្ទះ អោយតាមដានពតិមានទាំងនោះ។

*វេទិកាពិភាក្សា*

ទទ្ធិមនឹងធ្វើសកម្មភាពទាំងពីរខាងដើម គេត្រូវរៀបចំអោយមានការជជែកពិភាក្សាអន្តរ-ស្រករមនុស្សជាមួយនិរទេសជន។ ការងារផ្ទេរចំណេះ ចងចាំនេះត្រូវធ្វើជាពីរផ្នែក : ស្រាវជ្រាវរកការពិត និងសរសេរប្រវត្តិសាស្ត្រឡើងវិញ។ ការងារនេះមានលក្ខណៈងាយស្រួល ទេនៅឯបរទេស ប៉ុន្តែនៅក្នុងប្រទេសដើមកំណើតវិញ គឺត្រូវមានការត្រួតពិនិត្យអត្ថបទជាមុនសិន។ ការងារនេះ ក៏ជាការផ្តល់ ឱកាសដល់យុវជនអោយសិក្សាពីប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងចេះសួរ

ជជីកអំពីព្រឹត្តការណ៍នៅប្រទេសកម្ពុជា នៅក្នុង គ្រួសាររបស់ខ្លួន។ វេទិកាពិភាក្សានេះអាចនឹងធ្វើឡើងនៅតាម សាលា ភាសា ឬ មជ្ឈមណ្ឌលវប្បធម៌។

### គ. ស្វះស្វែងរកធនធាន អោយបានគ្រប់គ្រាន់ ដើម្បីធានានិរន្តរភាព នៃសកម្មភាព

ដោយសារធនធានសំភារៈ ហិរញ្ញវត្ថុនិងធនធានមនុស្សតិចតួច សហគមន៍និរទេសជនមានការលំបាកជាខ្លាំងក្នុងការគ្រប់គ្រងអោយបានទៀងទាត់ ចំពោះសមាគមជនរងគ្រោះ និង មានការលំបាក ក្នុងការធានាក្តីសង្ឃឹម របស់សមាគមទាំងនោះផងដែរ។ ទឹកប្រាក់ដែលផ្តល់ចំពោះសមាគមទាំងនេះ គឺជាប្រាក់ផ្ទាល់បានមកពីការរៃអង្គាស ពីសមាជិក បានមកពីអំណោយ បានមកពីកម្រៃដែលរកបាន ក្នុងឱកាសមានព្រឹត្តិការណ៍ផ្សេងៗ។ល។ ជាទូទៅ ប្រាក់នេះមិនគ្រប់គ្រាន់សំរាប់ទ្រទ្រង់សោហ៊ុយដែលចំណាយក្នុងការដាក់ពាក្យបណ្តឹងទេ។ សោហ៊ុយចំណាយទាំងនេះ ក្នុងរយៈពេលយូរបានបង្កការលំបាកដោយសារតែការយឺតយ៉ាវនៃនិតិវិធីតុលាការ និងបានធ្វើអោយជនរងគ្រោះ បាក់ទឹកចិត្ត និង ធ្វើអោយចុះខ្សោយដល់សកម្មភាពបំផុសទៀតផង។

មានវិធីជាច្រើន សំរាប់ដោះស្រាយ :

*ជំនួយភស្តុភារ និង ការចូលរួមរបស់អង្គការក្រៅរដ្ឋាភិបាល នៃប្រទេសជាម្ចាស់ផ្ទះ*

ការរីកចំរើន នៃចលនា និងការទាមទារផ្នែកនយោបាយ នៅលើឆាកអន្តរជាតិ បានជំរុញអោយសហគមន៍នានា ធ្វើការចាត់តាំងអោយកាន់តែប្រសើរឡើងៗ។ ការជួយឧបត្ថម្ភ របស់អង្គការមនុស្សធម៌ និង អង្គការក្រៅរដ្ឋាភិបាលជំនាញខាងសិទ្ធិមនុស្ស បានធ្វើអោយ សហគមន៍ទាំងនោះ ទទួលបានការយកចិត្តទុកដាក់[៦៤]។ សមាគមជនរងគ្រោះ នៅឯបរទេស ទទួលបានការឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាលនានា និង ពីប្រជាជននៃប្រទេសជាម្ចាស់ផ្ទះផងដែរ។ លើសពីនេះទៀត ការឧបត្ថម្ភទាំងនេះ បានផ្តល់ដល់សមាគមទាំងនេះ នូវលទ្ធភាពធ្វើការតវ៉ាតាមផ្លូវច្បាប់ និងធ្វើសកម្មភាពផ្សព្វផ្សាយ តាមរយៈបណ្តាញឃោសនាទៀតផង។ ដោយឡែក ការគាំទ្រផ្លូវចិត្ត និង ការយកចិត្តទុកដាក់ ស្តាប់ការតវ៉ារបស់ជនរងគ្រោះ បានធ្វើអោយពួកគេ (ជនរងគ្រោះ) អាចចេញផុតពីភាពឯកោ និង ក្លាយជាកត្តានៃការបំផុសចលនាផងដែរ។ ជាធម្មតា ការជួយឧបត្ថម្ភនេះត្រូវបានផ្តល់ ដោយសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ អង្គការលើកលែងទោសអន្តរជាតិ សម្ព័ន្ធសិទ្ធិមនុស្ស។ល។

*ការដាក់គំរោងជូនទៅប្រទេសផ្តល់ជំនួយ*

សកម្មភាពផ្សព្វផ្សាយនិងកិច្ចពិភាក្សា ដើម្បីស្វែងរកយុត្តិធម៌ អាចជាកម្មវត្ថុនៃការសុំជំនួយឧបត្ថម្ភ ពីបណ្តាប្រទេសផ្តល់ជំនួយក្នុងក្របខ័ណ្ឌនៃកម្មវិធីសិទ្ធិមនុស្ស នៃកម្មវិធីលើកដំកើងលទ្ធិប្រជាធិបតេយ្យ និង ការប្រយុទ្ធប្រឆាំងនិទណ្ឌភាព។

---

[៦៤] សង់តាល់ ប៉រដឺ បេណាយុន, ដូមីនិក ស្នាប់ភ័រ, *សហគមន៍និរទេសជន និង ប្រជាជាតិ,* អូឌីល ហ្សាកុប ប៉ារីស ២០០៥ ទំព័រ ១១៨។

សហគមន៍និរទេសជន មានសក្តានុពល ឬ តួនាទីមួយ ដែលត្រូវពង្រីកនៅលើឆាកអន្តរជាតិ ដូច្នេះ វាជាការសមស្របណាស់ ក្នុងការទទួលបានមូលនិធិគាំទ្រ ដើម្បីធ្វើការផ្សព្វផ្សាយ និង រៀបចំកិច្ចពិភាក្សានានា។

*លទ្ធភាពផ្តល់សក្ខីកម្មពីចម្ងាយ*

ទាក់ទិននឹងនិតិវិធីផ្តល់សក្ខីកម្ម ក្នុងក្របខ័ណ្ឌនៃការកាត់ទោសដោយតុលាការអន្តរជាតិ ដែលត្រូវចំណាយសោហ៊ុយធ្វើដំណើរនោះ គេត្រូវតែផ្តល់ប្រាក់ ដើម្បីបញ្ជូនអ្នកស៊ើបអង្កេត ទៅបរទេស ដើម្បីប្រមូលភស្តុតាង និង សក្ខីកម្ម។ មាត្រា ២៦ នៃបទបញ្ជាផ្ទៃក្នុងរបស់តុលាការកាត់ទោសពួកខ្មែរក្រហម ក៏បានគ្រោងពីលទ្ធភាពផ្តល់សក្ខីកម្មតាមរយៈរូបភាពវីដេអូដែរ។ ប្រការនេះ ចាយសោហ៊ុយតិចទាំងសងខាង[៦៥]។

# ៥. សេចក្តីសន្និដ្ឋាន

មកដល់បច្ចុប្បន្ននេះ មានការយកចិត្តទុកដាក់តិចណាស់ ចំពោះតួនាទី របស់សហគមន៍និរទេសជន នៅក្នុងដំណើរការស្វែងរកយុត្តិធម៌អន្តរកាល។ ការសិក្សាខ្លីនេះ បញ្ជាក់ពីការរួមចំណែកដ៏សំខាន់ របស់សហគមន៍និរទេសជនកម្ពុជា រស់នៅប្រទេសបារាំង និង បែលហ្ស៊ិក ក្នុងការកាត់ទោសពួកប្រព្រឹត្តឧក្រិដ្ឋកម្ម ក្រោមរបបខ្មែរក្រហម។ ពាក្យបណ្តឹងចំពោះតុលាការបែលហ្ស៊ិក និង បារាំង លទ្ធផលនៃការស៊ើបអង្កេតពីឧក្រិដ្ឋកម្ម និង ការចូលរួមរបស់ជនរងគ្រោះ គឺសុទ្ធតែជួយដល់ការបង្កើតតុលាការកាត់ទោសពួកខ្មែរក្រហម និង ការប្រព្រឹត្តទៅ របស់តុលាការនេះ។ ក៏ប៉ុន្តែ ដោយលក្ខណៈជាជនភៀសខ្លួន សហគមន៍និរទេសជនបែរជាមានតួនាទីមួយ មិនច្បាស់លាស់ទៅវិញ។ នៅក្នុងផ្ទៃសហគមន៍ ដែលបាក់ស្បាត ដែលឯកោ នៅក្នុងប្រទេសជាម្ចាស់ផ្ទះ ដែលរស់នៅដាច់ឆ្ងាយពីជនរួមជាតិរស់នៅក្នុងប្រទេសដើមកំណើត ទំនាក់ទនងអន្តរបុគ្គល មានច្រើនបែបណាស់។ ទំនាក់ទំនងរវាងសហគមន៍នានា ដែលចង់ស្វែងរកយុត្តិធម៌ ជាមួយជនរងគ្រោះ រស់នៅប្រទេសកម្ពុជា គួរតែត្រូវបានលើកទឹកចិត្ត និង ធ្វើអោយកាន់តែស្និតស្នាល ស៊ីជំរៅឡើង។

ការរីកចំរើន នៃការប្រឹងប្រែង នៅក្នុងផ្ទៃសហគមន៍ និង រវាងសហគមន៍នានា អាចបង្កឱកាសធ្វើការផ្លាស់ប្តូរមតិគ្នា ដើម្បីយល់អោយកាន់តែច្បាស់ អំពីមិតក ដ៏សោកសៅ ដែលបន្សល់ទុក ដោយឧក្រិដ្ឋកម្ម ក្នុងអតីតកាល ដែលនៅតែបន្តប៉ះពាល់ដល់សហគមន៍ទាំងនោះ រហូតដល់សព្វថ្ងៃ។ កិច្ចប្រឹងប្រែងទាំងនោះ ក៏អាចអោយបង្កើនកិច្ចពិភាក្សាស្តីពីមធ្យោបាយបំពេញបន្ថែមគំនិតផ្តួចផ្តើមផ្លូវច្បាប់ ដើម្បីគាំទ្រ អោយកាន់តែមានប្រសិទ្ធិភាព ចំពោះដំណើរការស្វែងរកយុត្តិធម៌។

[៦៥] មាត្រា ២៦.១ នៃបទបញ្ជាផ្ទៃក្នុង ចែងថា : *‹‹ចម្លើយរបស់សាក្សីណាមួយ ឬ របស់ជំនាញការណាម្នាក់ ក្នុងពេលស៊ើបអង្កេត ឬ ក្នុងពេលសវនាការ ត្រូវបានធ្វើឡើងដោយជននោះផ្ទាល់ បើសិនជាអាចធ្វើបាន។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេត និង តុលាការកាត់ទោសពួកខ្មែរក្រហម អាចអនុញ្ញាតអោយសាក្សីណាម្នាក់ ដាក់ចម្លើយតាមមធ្យោបាយបច្ចេកទេសដែលប្រើ អាចអោយសហចៅក្រម អាចអនុញ្ញាតអោយសាក្សីណាម្នាក់ដាក់ចម្លើយ តាមមធ្យោបាយបច្ចេកទេ ដែលប្រើអាចអោយសហចៅក្រមស៊ើបអង្កេត តុលាការតុលាការកាត់ទោសពួកខ្មែរក្រហម និង ភាគីនានា សួរសាក្សី នៅពេលដែលគាត់ (សាក្សី) ដាក់ចម្លើយ។ មធ្យោបាយបច្ចេកទេស មិនត្រូវបានអនុញ្ញាតអោយប្រើទេ បើសិនជាមធ្យោបាយនេះ ធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ ››* ។